គណិតវិភាគ II

ភាគ ២

មូលដ្ឋានគ្រឹះ

គណិតវិភាគ

- មេរៀន និង លំហាត់
- សម្រាប់ត្រៀមប្រឡងសិស្សពូកែ
- និស្សិតគណិតវិទ្យា វិស្វកម្មសំណង់

រៀបរៀងដោយ ងា ពិសិដ្ឋ

អារម្ភកថា

សៀវភៅនេះត្រូវបានរៀបរៀងបន្តចេញពីសៀវភៅគណិតវិភាគ I ដែលត្រូវបានរៀបរៀងដោយខ្ញុំបាទនៅឆ្នាំ ២០១៤ ។ ខ្ញុំបាទរៀបរៀងសៀវភៅប្រភេទនេះបន្តក៏ព្រោះថាគណិតវិភាគជាផ្នែកមួយដ៏សំខាន់នៃវិទ្យាសាស្ត្រជាពិសេសគឺផ្នែកវិស្វកម្ម ។ មួយវិញទៀតគណិតវិភាគជាលំហាត់ដែលពេញនិយមបំផុតក្នុងការប្រឡងបាក់ឌុប និង អាហារូបករណ៍នានា ។

សៀវភៅនេះត្រូវបានចងក្រងឡើងដោយមានជំនួយពីឯកសារខ្មែរ និង បរទេសជាច្រើន ។ ក្នុងសៀវភៅនេះខ្ញុំបាទសង្កត់ធ្ងន់ទៅលើការគណនាលីមីតនៃអនុគមន៍ លីមីតស្វ៊ីត រួមទាំងទ្រឹស្តីបទមួយចំនួនទៀតទាក់ទងនឹងដេរីវេ ។ សៀវភៅនេះត្រូវបានចែកចេញជាបីជំពូកសំខាន់ គឺ ទ្រឹស្តី និង មេរៀន ប្រធានលំហាត់ និង ដំណោះស្រាយ ។ ក្នុងផ្នែកទ្រឹស្តី និង មេរៀនខ្ញុំបាទបានលើកយកទ្រឹស្តីសំខាន់ៗមកបកស្រាយពន្យល់ដោយភ្ជាប់ជាមួយនឹងឧទាហរណ៍ដើម្បីឲ្យមិត្តអ្នកអានងាយស្រួលយល់ ។ ធ្វើបែបនេះគឺខ្ញុំបាទចង់ឲ្យមិត្តអ្នកអានយល់ច្បាស់ពីផ្នែកមេរៀនជាមុនសិនមុននឹងចាប់ផ្តើមធ្វើលំហាត់ ។ ក្នុងផ្នែកប្រធានលំហាត់វិញខ្ញុំបានដកស្រង់លំហាត់ចេញពីសៀវភៅនានា និង លំហាត់ធ្លាប់ប្រឡងចេញមួយចំនួនមកដាក់ជាបញ្ហាដើម្បីឲ្យមិត្តអ្នកអានធ្វើការត្រិះរិះពិចារណា ។ ក្នុងផ្នែកនេះសូមមិត្តអ្នកអានព្យាយាមគិតឲ្យអស់ពីសមត្ថភាពជាមុនសិន មុននឹងមើលដំណោះស្រាយលំហាត់ទាំងនោះ ។ រីឯផ្នែកដំណោះស្រាយវិញ ខ្ញុំបាទបានខិតខំបកស្រាយចម្លើយនៃលំហាត់ដោយផ្ចិតផ្ចង់ដើម្បីឲ្យមិត្តអ្នកអានងាយយល់ ងាយចាំពីគន្លឹះក្នុងការដោះស្រាយ ។

ក្នុងនាមជាអ្នករៀបរៀងសៀវភៅមួយក្បាលនេះ ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថាសៀវភៅនេះនឹងក្លាយជាឯកសារដ៏ល្អមួយសម្រាប់មិត្តអ្នកអាន ជាពិសេសប្អូនៗដែលកំពុងតែត្រៀមប្រឡងបាក់ឌុប អាហារូបករណ៍ និង សិស្សពូកែជាដើម ។ ជាចុងក្រោយ យើងខ្ញុំមានតែសូមអរគុណដល់មិត្តអ្នកអានដែលតែងតែគាំទ្រស្នាដៃសៀវភៅដែលរៀបរៀងដោយខ្ញុំបាទកន្លងមក។ សូមអរគុណ!

ភ្នំពេញ ០១ ខែធ្នូ ឆ្នាំ ២០១៧

រៀបរៀងដោយ ជា ពិសិដ្ឋ

មាតិកា

ជំពូក 1

ទ្រឹស្តីបទ និងគន្លឹះសំខាន់ៗ

1 លីមីតរាងមិនកំណត់ $\frac{0}{0}$

1.1 ប្រភាគសនិទាន

ជាទូទៅ
ដើម្បីគណនាលីមីតរាងមិនកំណត់ $\frac{0}{0}$ ចំពោះប្រភាគសនិទាន $\frac{f(x)}{g(x)}$ ពេល $x \to a$ គេត្រូវ
+ដាក់ភាគយក ($f(x)$) និង ភាគបែង($g(x)$) ជាកត្តា
+ សម្រួលកត្តារួមចោល ($x-a$ ជាកត្តារួម)
+ គណនាលីមីតនៃកន្សោមថ្មី ។

ឧទាហរណ៍ ១
គណនា $\lim_{x\to 1} \frac{x^3+x^2-3x+1}{x^4+2x^3-3}$ ។
ចម្លើយ

យើងមាន

$$\begin{aligned}\lim_{x\to1}\frac{x^3+x^2-3x+1}{x^4+2x^3-3} &= \lim_{x\to1}\frac{x^3-x^2+2x^2-2x-x+1}{x^4-x^3+3x^3-3}\\ &= \lim_{x\to1}\frac{x^2(x-1)+2x(x-1)-(x-1)}{x^3(x-1)+3(x^3-1)}\\ &= \lim_{x\to1}\frac{(x-1)\left(x^2+2x-1\right)}{x^3(x-1)+3(x-1)(x^2+x+1)}\\ &= \lim_{x\to1}\frac{(x-1)\left(x^2+2x-1\right)}{(x-1)[x^3+3(x^2+x+1)]}\\ &= \lim_{x\to1}\frac{x^2+2x-1}{x^3+3(x^2+x+1)}=\frac{1+2-1}{1+9}=\frac{2}{10}=\frac{1}{5}\end{aligned}$$

ឧទាហរណ៍ ២

គណនា $\lim_{x\to1}\frac{1-x^2}{x^4-x^3+2x^2-2x}$ ។

ចម្លើយ

យើងមាន

$$\begin{aligned}\lim_{x\to1}\frac{1-x^2}{x^4-x^3+2x^2-2} &= \lim_{x\to1}\frac{(1-x)(1+x)}{x^3(x-1)+2(x^2-1)}\\ &= \lim_{x\to1}\frac{-(x-1)(x+1)}{x^3(x-1)+2(x-1)(x+1)}\\ &= \lim_{x\to1}\frac{-(x-1)(x+1)}{(x-1)[x^3+2(x+1)]}\\ &= \lim_{x\to1}\frac{-(x+1)}{x^3+2x+2}=-\frac{2}{5}\end{aligned}$$

1.2 ប្រភាគអសនិទាន

ដើម្បីគណនាលីមីតរាងមិនកំណត់ $\frac{0}{0}$ ចំពោះប្រភាគអសនិទានគេត្រូវ

+បំបាត់រ៉ាឌីកាល់ (បើរ៉ាឌីកាល់នៅភាគយកបំបាត់នៅភាគយក បើរ៉ាឌីកាល់នៅភាគបែបបំបាត់នៅភាគបែង)

1. ចំពោះរឹសការេគេគុណនឹងកន្សោមឆ្លាស់ដើម្បីឲ្យចូលរូបមន្ត $a^2-b^2=(a-b)(a+b)$ + បើមាន $a-b$ គុណថែមនឹង $a+b$
   + បើមាន $a+b$ គុណថែមនឹង $a-b$

2. ចំពោះរឹសគូបគេគុណនឹងកន្សោមបំពេញដើម្បីឲ្យចូលរូបមន្ត
   $a^3-b^3=(a-b)(a^2+ab+b^2)$
   រឺ $a^3+b^3=(a+b)(a^2-ab+b^2)$ ។

+ក្រោយពីបំបាត់រ៉ាឌីកាល់រួច គេនឹងទទួលបានកត្តារួម ។ សម្រួលកត្តារួមនេះចោល
+គណនាលីមីតនៃកន្សោមថ្មី ។
សម្គាល់
រូបមន្តទូទៅសម្រាប់បំបាត់រ៉ាឌីកាល់ $a^n-b^n=(a-b)(a^{n-1}+a^{n-2}b+\ldots+ab^{n-2}+b^{n-1})$
រឺ $a^n+b^n=(a-b)(a^{n-1}-a^{n-2}b+\ldots-ab^{n-2}+b^{n-1})$ ។

ឧទាហរណ៍ ១

គណនា $\lim\limits_{x\to 0}\dfrac{\sqrt{x+1}-1}{x}$ ។

ចម្លើយ

យើងមាន

$$\begin{aligned}\lim_{x\to 0}\frac{\sqrt{x+1}-1}{x}&=\lim_{x\to 0}\frac{\left(\sqrt{x+1}-1\right)\left(\sqrt{x+1}+1\right)}{x\left(\sqrt{x+1}+1\right)}\\&=\lim_{x\to 0}\frac{x+1-1}{x\left(\sqrt{x+1}+1\right)}=\lim_{x\to 0}\frac{x}{x\left(\sqrt{x+1}+1\right)}\\&=\lim_{x\to 0}\frac{1}{\sqrt{x+1}+1}=\frac{1}{2}\end{aligned}$$

ឧទាហរណ៍ ២

គណនា $\lim\limits_{x\to 1}\dfrac{\sqrt[3]{x}-1}{x^2-3x+2}$ ។

ចម្លើយ

យើងមាន

$$\begin{aligned}\lim_{x\to 1}\frac{\sqrt[3]{x}-1}{x^2-3x+2}&=\lim_{x\to 1}\frac{(\sqrt[3]{x}-1)\left(\sqrt[3]{x^2}+\sqrt[3]{x}+1\right)}{(x-1)(x-2)\left(\sqrt[3]{x^2}+\sqrt[3]{x}+1\right)}\\&=\lim_{x\to 1}\frac{x-1}{(x-1)(x-2)\left(\sqrt[3]{x^2}+\sqrt[3]{x}+1\right)}\\&=\lim_{x\to 1}\frac{1}{(x-2)\left(\sqrt[3]{x^2}+\sqrt[3]{x}+1\right)}\\&=\frac{1}{(-1)(3)}=-\frac{1}{3}\end{aligned}$$

1.3 ត្រីកោណមាត្រ

ជាទូទៅ

$\lim_{x\to 0}\frac{\sin x}{x}=1$ $\lim_{x\to 0}\frac{1-\cos x}{x}=0$ $\lim_{x\to 0}\frac{\tan x}{x}=1$

$\lim_{x\to 0}\frac{1-\cos x}{x^2}=\frac{1}{2}$

សម្រាយ

+បង្ហាញថា $\lim_{x\to 0}\frac{\sin x}{x}=1$



តាមរូបគេបាន $S_{\triangle OMN}\le S_{\text{ចម្រៀកថាស } OMN}\le S_{\triangle OTN}$

ដោយ $S_{\triangle OMN}=\frac{1}{2}\times ON\times MH=\frac{1}{2}\sin x$

$S_{\triangle OTN}=\frac{1}{2}\times ON\times TN=\frac{1}{2}\tan x$

តាមសមាមាត្រ

2π ត្រូវគ្នានឹងក្រឡាផ្ទៃ $\pi r^2=\pi$

x ត្រូវគ្នានឹងក្រឡាផ្ទៃ $S_{\text{ចម្រៀកថាស}OMN}$

គេបាន $S_{\text{ចម្រៀកថាស}OMN}=\frac{x\times\pi}{2\pi}=\frac{x}{2}$

យើងបាន $\frac{1}{2}\sin x\le\frac{x}{2}\le\frac{1}{2}\tan x\Rightarrow\sin x\le x\le\tan x$

+ចំពោះ $0<x<\frac{\pi}{2}$ យើងបាន $\sin x>0$ នោះ $1\le\frac{x}{\sin x}\le\frac{1}{\cos x}$

$\Rightarrow\cos x\le\frac{\sin x}{x}\le 1$

ដោយ $\lim_{x\to 0^+}\cos x=\cos 0=1$ និង $\lim_{x\to 0^+}1=1$

គេបាន $\lim\limits_{x\to 0^+}\frac{\sin x}{x}=1$
+ចំពោះ $-\frac{\pi}{2}<x<0$
យក $t=-x$ នោះ $0<t<\frac{\pi}{2}$ គេបាន

$$\lim_{t\to 0^+}\frac{\sin t}{t}=1$$
$$\Rightarrow \lim_{x\to 0^-}\frac{\sin(-x)}{-x}=1$$
$$\Rightarrow \lim_{x\to 0^-}\frac{-\sin x}{-x}=1$$
$$\Rightarrow \lim_{x\to 0^-}\frac{\sin x}{x}=1$$

ដូចនេះ $\lim\limits_{x\to 0}\frac{\sin x}{x}=1$
+$\lim\limits_{x\to 0}\frac{1-\cos x}{x}=0$
យើងមាន

$$\lim_{x\to 0}\frac{1-\cos x}{x}=\lim_{x\to 0}\frac{2\sin^2\frac{x}{2}}{x}$$
$$=\lim_{x\to 0}2\times\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\right)^2\times\frac{\left(\frac{x}{2}\right)^2}{x}$$
$$=\lim_{x\to 0}\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\right)^2\times\frac{x}{2}=0$$

+$\lim\limits_{x\to 0}\frac{\tan x}{x}=1$
យើងមាន $\lim\limits_{x\to 0}\frac{\tan x}{x}=\lim\limits_{x\to 0}\frac{\frac{\sin x}{\cos x}}{x}=\lim\limits_{x\to 0}\frac{1}{\cos x}\times\frac{\sin x}{x}=\frac{1}{\cos 0}\times 1=1$
+$\lim\limits_{x\to 0}\frac{1-\cos x}{x^2}=\frac{1}{2}$
យើងមាន

$$\lim_{x\to 0}\frac{1-\cos x}{x^2}=\lim_{x\to 0}\frac{2\sin^2\frac{x}{2}}{\left(\frac{x}{2}\right)^2}\times\left(\frac{x}{2}\right)^2\times\frac{1}{x^2}$$
$$=\lim_{x\to 0}2\times\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\right)^2\times\frac{1}{4}=\frac{1}{2}$$

ឧទាហរណ៍ ១
គណនា $\lim\limits_{x\to 0}\dfrac{x+\sin x}{2x-\sin x}$ ។
ចម្លើយ
យើងមាន $\lim\limits_{x\to 0}\dfrac{x+\sin x}{2x-\sin x}=\lim\limits_{x\to 0}\dfrac{\frac{x+\sin x}{x}}{\frac{2x-\sin x}{x}}=\lim\limits_{x\to 0}\dfrac{1+\frac{\sin x}{x}}{2-\frac{\sin x}{x}}=\dfrac{1+1}{2-1}=2$
ឧទាហរណ៍ ២
គណនា $\lim\limits_{x\to 0}\dfrac{1-\cos 2x}{1-\cos 4x}$ ។
ចម្លើយ
យើងមាន

$$\begin{aligned}\lim_{x\to 0}\frac{1-\cos 2x}{1-\cos 4x}&=\lim_{x\to 0}\frac{2\sin^2 x}{2\sin^2 2x}\\&=\lim_{x\to 0}\left(\frac{\sin x}{\sin 2x}\right)^2\\&=\lim_{x\to 0}\left(\frac{\sin x}{x}\times\frac{2x}{\sin 2x}\times\frac{1}{2}\right)^2=\left(\frac{1}{2}\right)^2=\frac{1}{4}\end{aligned}$$

1.4 អនុគមន៍អិចស្ប៉ូណង់ស្យែល

> **ជាទូទៅ** $\lim\limits_{x\to 0}\dfrac{e^x-1}{x}=1$ ។

សម្រាយ
តាង $t=e^x-1\Rightarrow e^x=1+t\Rightarrow x=\ln(1+t)$
ពេល $x\to 0$ នោះ $t\to 0$
គេបាន $\lim\limits_{x\to 0}\dfrac{e^x-1}{x}=\lim\limits_{t\to 0}\dfrac{t}{\ln(1+t)}=\lim\limits_{t\to 0}\dfrac{1}{\frac{1}{t}\ln(1+t)}=\lim\limits_{t\to 0}\dfrac{1}{\ln(1+t)^{\frac{1}{t}}}=\dfrac{1}{\ln e}=1$
ឧទាហរណ៍ ១
គណនា $\lim\limits_{x\to 0}\dfrac{e^x-\cos x}{x}$ ។
ចម្លើយ
យើងមាន $\lim\limits_{x\to 0}\dfrac{e^x-\cos x}{x}=\lim\limits_{x\to 0}\dfrac{e^x-1+1-\cos x}{x}=\lim\limits_{x\to 0}\dfrac{e^x-1}{x}+\dfrac{1-\cos x}{x}=1+0=1$
ឧទាហរណ៍ ២

គណនា $\lim_{x\to 0}\frac{e^{ax}+e^{bx}+e^{cx}-3}{x}$ ចំពោះ a,b និង $c\neq 0$។
ចម្លើយ
យើងមាន

$$\begin{aligned}\lim_{x\to 0}\frac{e^{ax}+e^{bx}+e^{cx}-3}{x}&=\lim_{x\to 0}\frac{e^{ax}-1+e^{bx}-1+e^{cx}-1}{x}\\&=\lim_{x\to 0}\left(\frac{e^{ax}-1}{x}\right)+\left(\frac{e^{bx}-1}{x}\right)+\left(\frac{e^{cx}-1}{x}\right)\\&=\lim_{x\to 0}\left(\frac{e^{ax}-1}{ax}\right)a+\left(\frac{e^{bx}-1}{bx}\right)b+\left(\frac{e^{cx}-1}{cx}\right)c=a+b+c\end{aligned}$$

1.5 អនុគមន៍លោការីតនេពែ

ជាទូទៅ $\lim_{x\to 0}\frac{\ln(1+x)}{x}=1$ ។

សម្រាយ
យើងមាន $\lim_{x\to 0}\frac{\ln(1+x)}{x}=\lim_{x\to 0}\ln(1+x)^{\frac{1}{x}}=\ln e=1$
ឧទាហរណ៍
គណនា $\lim_{x\to 0}\frac{\ln(\cos x)}{x^2}$ ។
ចម្លើយ
យើងមាន

$$\begin{aligned}\lim_{x\to 0}\frac{\ln(\cos x)}{x^2}&=\lim_{x\to 0}\frac{\ln(1+\cos x-1)}{\cos x-1}\times\frac{\cos x-1}{x^2}\\&=-\lim_{x\to 0}\frac{\ln(1+\cos x-1)}{\cos x-1}\times\frac{1-\cos x}{x^2}\\&=-1\times\frac{1}{2}=-\frac{1}{2}\end{aligned}$$

2 លីមីតរាងមិនកំណត់ $\frac{\infty}{\infty}$

វិធាន ដើម្បីគណនាលីមីតរាងមិនកំណត់ $\frac{\infty}{\infty}$ នៃប្រភាគ $\frac{f(x)}{g(x)}$ គេត្រូវ
+ចាប់តួដែលមានដឺក្រេខ្ពស់នៃភាគយក និង ភាគបែងជាកត្តា
+ សម្រួលកត្តារួមចោល
+គណនាលីមីតនៃកន្សោមថ្មី ។

ឧទាហរណ៍ ១
គណនា $\lim_{x\to+\infty}\frac{x^2+3x+2}{x^2+4x-2}$ ។
ចម្លើយ
យើងមាន $\lim_{x\to+\infty}\frac{x^2+3x+2}{x^2+4x-2}=\lim_{x\to+\infty}\frac{1+\frac{3}{x}+\frac{2}{x^2}}{1+\frac{4}{x}-\frac{2}{x^2}}=\frac{1+0+0}{1+0-0}=1$

ឧទាហរណ៍ ២
គណនា $\lim_{x\to+\infty}\frac{a_mx^m+a_{m-1}x^{m-1}+\ldots+a_1x+a_0}{b_nx^n+b_{n-1}x^{n-1}+\ldots+b_1x+b_0}$ ។
ចម្លើយ
យើងមាន

$$\begin{aligned}A&=\lim_{x\to+\infty}\frac{a_mx^m+a_{m-1}x^{m-1}+\ldots+a_1x+a_0}{b_nx^n+b_{n-1}x^{n-1}+\ldots+b_1x+b_0}\\&=\lim_{x\to+\infty}\frac{x^m\left(a_m+\frac{a_{m-1}}{x}+\ldots+\frac{a_1}{x^{m-1}}+\frac{a_0}{x^m}\right)}{x^n\left(b_n+\frac{b_{n-1}}{x}+\ldots+\frac{b_1}{x^{n-1}}+\frac{b_0}{x^n}\right)}\\&=\lim_{x\to+\infty}\frac{a_mx^m}{b_nx^n}=\lim_{x\to+\infty}\frac{a_m}{b_n}x^{m-n}\end{aligned}$$

+ ចំពោះ $m>n$ គេបាន $A=+\infty$
+ ចំពោះ $m<n$ គេបាន $A=0$
+ ចំពោះ $m=n$ គេបាន $A=\frac{a_m}{b_n}$

3 លីមីតរាងមិនកំណត់ $\infty - \infty$

3.1 ចំពោះពហុធា

វិធាន ដើម្បីគណនាលីមីតរាងមិនកំណត់ $\infty - \infty$ ចំពោះពហុធាយើងត្រូវចាប់តួដែលមានដឺក្រេខ្ពស់ជាកត្តា ។

ឧទាហរណ៍
គណនា $\lim\limits_{x\to+\infty}(x^3+x^2-2)$ ។

ចម្លើយ
យើងមាន $\lim\limits_{x\to+\infty}(x^3+x^2-2) = \lim\limits_{x\to+\infty} x^3\left(1+\frac{1}{x}-\frac{2}{x^2}\right) = +\infty$

3.2 អនុគមន៍អសនិទាន

វិធាន ដើម្បីគណនាលីមីតរាងមិនកំណត់ $\infty - \infty$ នៃអនុគមន៍អសនិទានគេត្រូវបំបាត់រ៉ាឌីកាល់ ។ ក្រោយពីបំបាត់រ៉ាឌីកាល់រួច គេនឹងទទួលបានកន្សោមថ្មីដែលលីមីតរបស់វាមានរាងមិនកំណត់ $\frac{\infty}{\infty}$ ។ អនុវត្តការគណនាលីមីតនេះតាមចំណុច 2 យើងនឹងទទួលបានលទ្ធផល ។

ឧទាហរណ៍ ១
គណនា $\lim\limits_{x\to+\infty}\left(\sqrt{x^2+3x}-x\right)$ ។

ចម្លើយ
យើងមាន

$$\begin{aligned}
\lim_{x\to+\infty}\left(\sqrt{x^2+3x}-x\right) &= \lim_{x\to+\infty}\frac{x^2+3x-x^2}{\sqrt{x^2+3x}+x}\\
&= \lim_{x\to+\infty}\frac{3x}{\sqrt{x^2+3x}+x}\\
&= \lim_{x\to+\infty}\frac{3}{\sqrt{1+\frac{3}{x}}+1} = \frac{3}{2}
\end{aligned}$$

ឧទាហរណ៍ ២
គណនា $\lim\limits_{x\to+\infty}\left(\sqrt[3]{x^3-x}-\sqrt{x^2+x}\right)$ ។

ចម្លើយ

យើងមាន

$$\begin{aligned}\lim_{x\to+\infty}\left(\sqrt[3]{x^3-x}-\sqrt{x^2+x}\right) &= \lim_{x\to+\infty}\left(\sqrt[3]{x^3-x}-x\right)-\left(\sqrt{x^2+x}-x\right)\\ &= \lim_{x\to+\infty}\frac{x^3-x-x^3}{\sqrt[3]{\left(x^3-x\right)^2}+x\sqrt[3]{x^3-x}+x^2}+\frac{x^2+x-x^2}{\sqrt{x^2+x}+x}\\ &= \lim_{x\to+\infty}\frac{-x}{\sqrt[3]{\left(x^3-x\right)^2}+x\sqrt[3]{x^3-x}+x^2}+\frac{x}{\sqrt{x^2+x}+x}\\ &= \lim_{x\to+\infty}-\frac{x}{x^2\sqrt[3]{\left(1-\frac{1}{x^2}\right)^2}+x\sqrt[3]{x^3-x}+x^2}+\frac{1}{\sqrt{1+\frac{1}{x}}+1}\\ &= \lim_{x\to+\infty}-\frac{1}{x\sqrt[3]{\left(1-\frac{1}{x^2}\right)^2}+\sqrt[3]{x^3-x}+x}+\frac{1}{\sqrt{1+\frac{1}{x}}+1}=\frac{1}{2}\end{aligned}$$

4 លីមីតនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល

ជាទូទៅគេកំណត់យក $e=\lim_{n\to+\infty}\left(1+\frac{1}{n}\right)^n\sim 2.7182$ ។

ទ្រឹស្តីបទ $\lim_{x\to+\infty}\left(1+\frac{1}{x}\right)^x=e$ ។

សម្រាយ

5 លីមីតរាងមិនកំណត់ 1^∞

ដើម្បីគណនាលីមីតរាងមិនកំណត់ 1^∞ គេប្រើ $\lim_{x\to\infty}\left(1+\frac{1}{x}\right)^x=e$ ។

ឧទាហរណ៍

គណនា $\lim_{x\to+\infty}\left(1+\frac{1}{x^2+x}\right)^{x^2}$ ។

ចម្លើយ

យើងមាន $\lim_{x\to+\infty}\left(1+\frac{1}{x^2+x}\right)^{x^2}=\lim_{x\to+\infty}\left[\left(1+\frac{1}{x^2+x}\right)^{x^2+x}\right]^{\frac{x^2}{x^2+x}}=e^{\lim_{x\to+\infty}\frac{x^2}{x^2+x}}=e$

6 The Stolz-Cesaro

ទ្រឹស្តីបទ
គេឲ្យ (a_n) និង (b_n) ជាស្វ៊ីតនៃចំនួនពិត ។ បើ (b_n) ជាស្វ៊ីតនៃចំនួនពិតវិជ្ជមានកើនទៅរក $+\infty$ និង $\lim_{n\to+\infty}\frac{a_{n+1}-a_n}{b_{n+1}-b_n}=l$ នោះ $\lim_{n\to+\infty}\frac{a_n}{b_n}=l$ ។

សម្រាយ
ដោយ $\lim_{n\to+\infty}\frac{a_{n+1}-a_n}{b_{n+1}-b_n}=l$
តាមនិយមន័យលីមីតយើងបាន $\forall\varepsilon>0,\exists N_\varepsilon\in\mathbb{N},\forall n\geq N_\varepsilon : l-\varepsilon<\frac{a_{n+1}-a_n}{b_{n+1}-b_n}<l+\varepsilon$
ដោយ (b_n) ជាស្វ៊ីតកើនដាច់ខាត នោះ $b_{n+1}-b_n>0$
យើងបាន $(l-\varepsilon)(b_{n+1}-b_n)<a_{n+1}-a_n<(l+\varepsilon)(b_{n+1}-b_n)$
ឧបមាថា k ជាចំនួនគត់ដែល $k\geq N_\varepsilon$ យើងបាន

$$
\begin{aligned}
(l-\varepsilon)\sum_{n=N_\varepsilon}^{k}(b_{n+1}-b_n)<\sum_{n=N_\varepsilon}^{k}(a_{n+1}-a_n)<(l+\varepsilon)\sum_{k=n_\varepsilon}^{k}(b_{n+1}+b_n)\\
(l-\varepsilon)(b_{k+1}-b_{N_\varepsilon})<a_{k+1}-a_{N_\varepsilon}<(l+\varepsilon)(b_{k+1}-b_{N_\varepsilon})\\
(l-\varepsilon)\left(1-\frac{b_{N_\varepsilon}}{b_{k+1}}\right)<\frac{a_{k+1}}{b_{k+1}}-\frac{a_{N_\varepsilon}}{b_{k+1}}<(l+\varepsilon)\left(1-\frac{b_{N_\varepsilon}}{b_{k+1}}\right)\\
(l-\varepsilon)\left(1-\frac{b_{N_\varepsilon}}{b_{k+1}}\right)+\frac{a_{N_\varepsilon}}{b_{k+1}}<\frac{a_{k+1}}{b_{k+1}}<(l+\varepsilon)\left(1-\frac{b_{N_\varepsilon}}{b_{k+1}}\right)+\frac{a_{N_\varepsilon}}{b_{k+1}}
\end{aligned}
$$

ដោយ b_k កើនទៅរក $+\infty$ យើងបាន $\lim_{k\to+\infty}\frac{b_{N_\varepsilon}}{b_{k+1}}=\lim_{k\to+\infty}\frac{a_{N_\varepsilon}}{b_{k+1}}=0$
នោះ $\lim_{k\to+\infty}\frac{a_{k+1}}{b_{k+1}}=l=\lim_{n\to+\infty}\frac{a_{n+1}-a_n}{b_{n+1}-b_n}$
ដូចនេះ $\lim_{n\to+\infty}\frac{a_n}{b_n}=l$

វិបាក
គេឲ្យ (a_n) ជាស្វ៊ីតនៃចំនួនពិតវិជ្ជមានដាច់ខាតដែល $\lim_{n\to+\infty}\frac{a_{n+1}}{a_n}=l$ ។
យើងបាន $\lim_{n\to+\infty}\sqrt[n]{a_n}=\lim_{n\to+\infty}\frac{a_{n+1}}{a_n}$ ។

សម្រាយ
តាមទ្រឹស្តីបទ The Stolz-Cesaro យើងបាន

$\lim\limits_{n\to+\infty}(\ln\sqrt[n]{a_n})=\lim\limits_{n\to+\infty}\frac{\ln a_n}{n}=\lim\limits_{n\to+\infty}\frac{\ln a_{n+1}-\ln a_n}{(n+1)-n}=\lim\limits_{n\to+\infty}\ln\left(\frac{a_{n+1}}{a_n}\right)=\ln l$

គេបាន $\lim\limits_{n\to+\infty}\sqrt[n]{a_n}=\lim\limits_{n\to+\infty}e^{\ln\sqrt[n]{a_n}}=e^{\lim\limits_{n\to+\infty}\ln\sqrt[n]{a_n}}=e^{\ln l}=l$

ឧទាហរណ៍ ១

គេឲ្យ (x_n) ជាស្វ៊ីតនៃចំនួនពិតដែល $x_n>0$ ចំពោះគ្រប់ $n\geq 1$ ។ បើគេដឹងថា $\lim\limits_{n\to+\infty}\frac{x_n}{n}=+\infty$

បង្ហាញថា $\lim\limits_{n\to+\infty}\frac{1}{\sqrt{n}}\sum_{k=1}^{n}\frac{1}{\sqrt{x_k}}=0$ ។

សម្រាយ

បង្ហាញថា $\lim\limits_{n\to+\infty}\frac{1}{\sqrt{n}}\sum_{k=1}^{n}\frac{1}{\sqrt{x_k}}=0$

តាមទ្រឹស្តីបទ The Stolz-Cesaro យើងបាន

$$\begin{aligned}\lim_{n\to+\infty}\frac{1}{\sqrt{n}}\sum_{k=1}^{n}\frac{1}{\sqrt{x_k}}&=\lim_{n\to+\infty}\frac{\sum_{k=1}^{n}\frac{1}{\sqrt{x_k}}}{\sqrt{n}}\\&=\lim_{n\to+\infty}\frac{\sum_{k=1}^{n+1}\frac{1}{\sqrt{x_k}}-\sum_{k=1}^{n}\frac{1}{\sqrt{x_k}}}{\sqrt{n+1}-\sqrt{n}}\\&=\lim_{n\to+\infty}\frac{\frac{1}{\sqrt{x_{n+1}}}}{\sqrt{n+1}-\sqrt{n}}\\&=\lim_{n\to+\infty}\frac{\sqrt{n+1}+\sqrt{n}}{\sqrt{x_n}}\\&=\lim_{n\to+\infty}\left(\sqrt{\frac{n+1}{x_n}}+\sqrt{\frac{n}{x_n}}\right)=0\end{aligned}$$

ព្រោះ $\lim\limits_{n\to+\infty}\frac{x_n}{n}=+\infty$

ដូចនេះ $\lim\limits_{n\to+\infty}\frac{1}{\sqrt{n}}\sum_{k=1}^{n}\frac{1}{\sqrt{x_k}}=0$

ឧទាហរណ៍ ២

គេឲ្យ (x_n) ជាស្វ៊ីតនៃចំនួនពិតកំណត់ដោយ $x_n=\frac{\sum_{k=1}^{n}kk!}{(n+1)!-1}$ ។

គណនា $\lim\limits_{n\to+\infty}x_n$ ។

ចម្លើយ

តាមទ្រឹស្តីបទ The Stolz-Cesaro យើងបាន

$$\begin{aligned}\lim_{n\to+\infty} x_n &= \lim_{n\to+\infty}\frac{\sum_{k=1}^{n} kk!}{(n+1)!-1}\\ &= \lim_{n\to+\infty}\frac{\sum_{k=1}^{n+1} kk!-\sum_{k=1}^{n} kk!}{(n+2)!-1-(n+1)!+1}\\ &= \lim_{n\to+\infty}\frac{(n+1)(n+1)!}{(n+1)(n+1)!}=1\end{aligned}$$

ដូចនេះ $\lim_{n\to+\infty} x_n = 1$

ឧទាហរណ៍ ៣

គេឲ្យ (x_n) ជាស្វីតនៃចំនួនពិតដែល $x_1=1$ និង $x_{n+1}=\sqrt{x_1+x_2+\ldots+x_n}$ ។

គណនា $\lim_{n\to+\infty}\frac{x_n}{n}$ ។

ចម្លើយ

ដោយ $x_1=1$ និង $x_{n+1}=\sqrt{x_1+x_2+\ldots+x_n}$

នោះ (x_n) ជាស្វីតកើន និង វិជ្ជមានជានិច្ច ហើយ $x_{n+1}^2=x_n^2+x_n$

ឧបមាថា (x_n) ជាស្វីតទាល់ នោះ (x_n) មានលីមីតតាងដោយ l

យើងបាន $l^2=l^2+l\Rightarrow l=0$ មិនពិត ព្រោះ $x_n\geq 1$ ចំពោះគ្រប់ $n\geq 1$

នេះបញ្ជាក់ថា (x_n) មិនមែនជាស្វីតទាល់ $\Rightarrow \lim_{n\to+\infty} x_n=+\infty$

តាមទ្រឹស្តីបទ The Stolz-Cesaro យើងបាន

$$\begin{aligned}\lim_{n\to+\infty}\frac{x_n}{n} &= \lim_{n\to+\infty}\frac{x_{n+1}-x_n}{n+1-n}\\ &= \lim_{n\to+\infty}\frac{x_{n+1}^2-x_n^2}{x_{n+1}+x_n}\\ &= \lim_{n\to+\infty}\frac{x_n}{x_{n+1}+x_n}\\ &= \lim_{n\to+\infty}\frac{1}{\frac{x_{n+1}}{x_n}+1}\end{aligned}$$

ម៉្យាងទៀត $x_{n+1}^2=x_n^2+x_n\Rightarrow\frac{x_{n+1}^2}{x_n}=1+\frac{1}{x_n}\Rightarrow\lim_{n\to+\infty}\frac{x_{n+1}^2}{x_n^2}=1$

យើងបាន $\lim_{n\to+\infty}\frac{x_{n+1}}{x_n}=1$

ដូចនេះ $\lim_{n\to+\infty}\frac{x_n}{n}=\frac{1}{1+1}=\frac{1}{2}$

ឧទាហរណ៍ ៤

គណនា $\lim_{n\to+\infty}\frac{\ln n!-n\ln n}{n}$ ។

ចម្លើយ

តាមទ្រឹស្តីបទ The Stolz-Cesaro យើងបាន

$$\begin{aligned}\lim_{n\to+\infty}\frac{\ln n!-n\ln n}{n}&=\lim_{n\to+\infty}\frac{\ln(n+1)!-(n+1)\ln(n+1)-\ln n!+n\ln n}{n+1-n}\\&=\lim_{n\to+\infty}[\ln(n+1)-(n+1)\ln(n+1)+n\ln n]\\&=\lim_{n\to+\infty}[-n\ln(n+1)+n\ln n]\\&=\lim_{n\to+\infty}-\frac{\ln\left(1+\frac{1}{n}\right)}{\frac{1}{n}}=-1\end{aligned}$$

ដូចនេះ $\lim_{n\to+\infty}\frac{\ln n!-n\ln n}{n}=-1$

7 ទ្រឹស្តីបទ Rolle

ទ្រឹស្តីបទ

គេឲ្យ f ជាអនុគមន៍ជាប់លើចន្លោះបិទ $[a,b]$ និង មានដេរីវេលើចន្លោះបើក (a,b) ដែល $f(a)=f(b)$ នោះមានចំនួនពិត $c\in(a,b)$ មួយយ៉ាងតិចដែល $f'(c)=0$ ។

សម្រាយ

យក $f(a)=f(b)=d$

+ បើ $f(x)=d$ ថេរចំពោះគ្រប់ $x\in[a,b]$ នោះ $f'(x)=0$ ចំពោះគ្រប់ $x\in[a,b]$

នេះបញ្ជាក់ថា មានចំនួនពិត $c\in(a,b)$ មួយយ៉ាងតិចដែល $f'(c)=0$

+ បើ $f(x)>d$ ចំពោះ $x\in(a,b)$ នោះ $f(x)$ មានតម្លៃអតិបរមាមួយយ៉ាងតិចត្រង់ $x=c\in(a,b)$

នេះបញ្ជាក់ថា មានចំនួនពិត $c\in(a,b)$ មួយយ៉ាងតិចដែល $f'(c)=0$

+ បើ $f(x)<d$ ចំពោះ $x\in(a,b)$ នោះ $f(x)$ មានតម្លៃអប្បបរមាយ៉ាងតិចត្រង់ $x=c\in(a,b)$

នេះបញ្ជាក់ថា មានចំនួនពិត $c\in(a,b)$ មួយយ៉ាងតិចដែល $f'(c)=0$

ឧទាហរណ៍ ១

គេឲ្យ f ជាអនុគមន៍កំណត់ដោយ $f(x)=x^2-3x+2$ ។

ក) រកអាប់ស៊ីសនៃចំណុចប្រសព្វតាងដោយ x_1,x_2 នៃក្រាបតាងអនុគមន៍ និង អ័ក្សអាប់ស៊ីស ។

ខ) បង្ហាញថាមានចំនួនពិត c មួយនៅចន្លោះ (x_1, x_2) ដែល $f'(c) = 0$ រួចគណនា c ។

ចម្លើយ

ក) រកអាប់ស៊ីសនៃចំណុចប្រសព្វតាងដោយ x_1, x_2 នៃក្រាបតាងអនុគមន៍ និង អ័ក្សអាប់ស៊ីស

បើ $f(x) = 0$ យើងបាន $x^2 - 3x + 2 = 0$

ដោយ $a+b+c = 1-3+2 = 0$ នោះ $x_1 = 1, x_2 = \frac{c}{a} = \frac{2}{1} = 2$

ដូចនេះ $x_1 = 1$ និង $x_2 = 2$

ខ) បង្ហាញថាមានចំនួនពិត c មួយនៅចន្លោះ (x_1, x_2) ដែល $f'(c) = 0$ រួចគណនា c

ដោយ $f(x_1) = f(1) = 0 = f(2) = f(x_2)$

តាមទ្រឹស្តីបទ Rolle មាន c មួយយ៉ាងតិចនៅចន្លោះ (x_1, x_2) ដែល $f'(c) = 0$

+គណនា c

ដោយ $f(x) = x^2 - 3x + 2 \Rightarrow f'(x) = 2x - 3$

បើ $f'(c) = 0 \Rightarrow 2c - 3 = 0 \Rightarrow c = \frac{3}{2} \in (1, 2)$

ដូចនេះ $c = \frac{3}{2}$

ឧទាហរណ៍ ២

ក) គេឲ្យ $f(x) = x^2 - 2x$ ។ បញ្ជាក់អត្ថិភាព និង រកគ្រប់ $c \in [0, 2]$ ដែល $f'(c) = 0$ ។

ខ) គេឲ្យ $f(x) = (x-3)(x+1)^2$។ បញ្ជាក់អត្ថិភាព និងរកគ្រប់ $c \in [-1, 3]$ដែល $f'(c) = 0$។

ចម្លើយ

ក) បញ្ជាក់អត្ថិភាព និង រកគ្រប់ $c \in [0, 2]$ ដែល $f'(c) = 0$

យើងមាន $f(x) = x^2 - 2x \Rightarrow f(0) = 0$ និង $f(2) = 2^2 - 2(2) = 0$

តាមទ្រឹស្តីបទ *Rolle* មាន $c \in [0, 2]$ ដែល $f'(c) = 0$

ម៉្យាងទៀត $f'(x) = 2x - 2$

ដោយ $f'(c) = 0 \Rightarrow 2c - 2 = 0 \Rightarrow c = 1 \in [0, 2]$

ដូចនេះ $c = 1$

ខ) បញ្ជាក់អត្ថិភាព និង រកគ្រប់ $c \in [-1, 3]$ ដែល $f'(c) = 0$

យើងមាន $f(x) = (x-3)(x+1)^2$

នោះ $f(-1) = (-1-3)(-1+1)^2 = 0$

នោះ $f(3) = (3-3)(3+1)^2 = 0$

តាមទ្រឹស្តីបទ Rolle មាន $c \in [-1, 3]$ ដែល $f'(c) = 0$

ដោយ

$$\begin{aligned} f'(x) &= (x+1)^2 + 2(x+1)(x-3) \\ &= (x+1)[(x+1) + 2(x-3)] \\ &= (x+1)(3x-2) \end{aligned}$$

តាម $f'(c)=0$ គេបាន $(c+1)(3c-2)=0 \Rightarrow c=-1, c=\frac{3}{2}$
ដូចនេះ $c \in \{-1, \frac{3}{2}\}$

៨ ទ្រឹស្តីបទតម្លៃមធ្យម

ទ្រឹស្តីបទ
គេឲ្យ f ជាអនុគមន៍ជាប់លើចន្លោះ $[a,b]$ និង មានដេរីវេលើ (a,b) ។ បង្ហាញថា មាន $c \in (a,b)$ មួយយ៉ាងតិចដែលបំពេញលក្ខខណ្ឌ $f'(c)=\frac{f(b)-f(a)}{b-a}$ ។

សម្រាយ
បន្ទាត់ដែលកាត់តាមចំណុច $A(a,f(a))$ និង $B(b,f(b))$ កំណត់ដោយ
$(l): y=\left[\frac{f(b)-f(a)}{b-a}\right](x-a)+f(a)$
យក $g(x)=f(x)-y=f(x)-\left[\frac{f(b)-f(a)}{b-a}\right](x-a)-f(a)$
ដោយ f ជាអនុគមន៍ជាប់លើចន្លោះ $[a,b]$ និង មានដេរីវេលើចន្លោះ (a,b)
យើងបាន g ក៏ជាអនុគមន៍ជាប់ និង មានដេរីវេលើ (a,b) ដែរ
ហើយ $g'(x)=f'(x)-\frac{f(b)-f(a)}{b-a}$
ម៉្យាងទៀត $g(a)=0=g(b)$
តាមទ្រឹស្តីបទ Rolle មាន $x \in (a,b)$ មួយយ៉ាងតិចដែលបំពេញលក្ខខណ្ឌ $g'(c)=0$
$\Rightarrow f'(c)-\frac{f(b)-f(a)}{b-a}=0$
ដូចនេះ $f'(c)=\frac{f(b)-f(a)}{b-a}$

ឧទាហរណ៍
បង្ហាញថា បន្ទាត់ប៉ះនឹងប៉ារ៉ាបូលតាងអនុគមន៍ $f(x)=x^2$ ត្រង់ $\frac{a+b}{2}$ ស្របទៅនឹងបន្ទាត់កាត់ប៉ារ៉ាបូលត្រង់ $A(a,a^2)$ និង $B(b^2,b)$ ។

ចម្លើយ
យើងមាន $f(x)=x^2$ ជាអនុគមន៍ជាប់ និង មានដេរីវេលើ $\mathbb{R}$
តាមទ្រឹស្តីបទតម្លៃមធ្យមមាន $c \in (a,b)$ មួយយ៉ាងតិចដែល $\frac{f(b)-f(a)}{b-a}=f'(c)$

គេបាន $f'(c)=\dfrac{f(b)-f(a)}{b-a}$ ជាមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះប៉ារ៉ាបូលត្រង់ $x=c$
ម៉្យាងទៀត $\dfrac{f(b)-f(a)}{b-a}$ ជាមេគុណប្រាប់ទិសនៃ (AB)
នោះ (AB) ស្របនឹងបន្ទាត់ប៉ះប៉ារ៉ាបូលត្រង់ $x=c$
ដោយ $f'(x)=2x \Rightarrow f'(c)=2c$
យើងបាន $2c=\dfrac{b^2-a^2}{b-a} \Rightarrow c=\dfrac{a+b}{2}$
ដូចនេះ បន្ទាត់ប៉ះប៉ារ៉ាបូលត្រង់ $c=\dfrac{a+b}{2}$ ស្របនឹងបន្ទាត់ (AB)

9 ទ្រឹស្ដីបទ Cauchy

ទ្រឹស្ដីបទ បើ f និង g ជាអនុគមន៍ជាប់លើ $[a,b]$ និង មានដេរីវេលើ (a,b) ដែល $g'(x)\neq 0$ ចំពោះគ្រប់ $x\in(a,b)$ ហើយ $g(a)\neq g(b)$ នោះមាន $c\in(a,b)$ ដែល $\dfrac{f(b)-f(a)}{g(b)-g(a)}=\dfrac{f'(c)}{g'(c)}$ ។

សម្រាយ

យក $h(x)=f(x)-kg(x)$ ដែល $h(a)=h(b)$
តាម $h(a)=h(b)$ យើងបាន $f(a)-kg(a)=f(b)-kg(b) \Rightarrow k=\dfrac{f(b)-f(a)}{g(b)-g(a)}$
ម៉្យាងទៀត f និង g ជាអនុគមន៍ជាប់លើ $[a,b]$ និង មានដេរីវេលើ (a,b) នោះ h ក៏ជាអនុគមន៍ជាប់លើ $[a,b]$ និង មានដេរីវេលើ (a,b) ដែរ
តាមទ្រឹស្ដីបទ Rolle មាន $c\in(a,b)$ ដែល $h'(c)=0$
ដោយ $h'(x)=f'(x)-kg'(x) \Rightarrow h'(c)=f'(c)-kg'(c)$
យើងបាន $f'(c)-kg'(c)=0 \Rightarrow k=\dfrac{f'(c)}{g'(c)}$
ដូចនេះ $\dfrac{f(b)-f(a)}{g(b)-g(a)}=\dfrac{f'(c)}{g'(c)}$

10 វិធាន L'Hospital

ទ្រឹស្តីបទ បើ f និង g ជាអនុគមន៍មានដេរីវេលើ voisinage នៃ a ដែល $f(a) = g(a) = 0$ និង $\lim_{x\to a}\frac{f'(x)}{g'(x)} = l$ នោះ $\lim_{x\to a}\frac{f(x)}{g(x)} = l$ ។

សម្រាយ

ដោយ $\lim_{x\to a}\frac{f'(x)}{g'(x)} = l$

យើងបាន $\forall\varepsilon > 0, \exists\eta > 0, \forall\zeta \in (a-\eta, a+\eta), \left|\frac{f'(\zeta)}{g'(\zeta)} - l\right| < \varepsilon$

ចំពោះ $x \in (a-\eta, a+\eta)$ តាមទ្រឹស្តីបទ Cauchy

មាន $\zeta \in (a,x)$ ពោលគឺ $\zeta \in (a-\eta, a+\eta)$ ដែល $\frac{f(x)-f(a)}{g(x)-g(a)} = \frac{f'(\zeta)}{g'(\zeta)}$

$\Rightarrow \frac{f(x)}{g(x)} = \frac{f'(\zeta)}{g'(\zeta)}$ ព្រោះ $f(x) = g(x) = 0$

គេបាន $\left|\frac{f(x)}{g(x)} - l\right| < \varepsilon$

ដូចនេះ $\lim_{x\to a}\frac{f(x)}{g(x)} = l$

ឧទាហរណ៍

គណនា

ក) $\lim_{x\to 0}\frac{x-\sin x}{x-\tan x}$

ខ) $\lim_{x\to 0}\frac{x-\sin x}{x^3}$ ។

ចម្លើយ

គណនា

ក) $\lim_{x\to 0}\frac{x-\sin x}{x-\tan x}$ រាងមិនកំណត់ $\frac{0}{0}$

តាមទ្រឹស្តីបទ L′Hospital យើងបាន

$$\begin{aligned}
\lim_{x\to 0}\frac{x-\sin x}{x-\tan x} &= \lim_{x\to 0}\frac{(x-\sin x)'}{(x-\tan x)'}\\
&= \lim_{x\to 0}\frac{1-\cos x}{1-1-\tan^2 x}\\
&= \lim_{x\to 0}\frac{1-\cos x}{-\tan^2 x}\\
&= \lim_{x\to 0}\frac{(1-\cos x)'}{(-\tan^2 x)'}\\
&= \lim_{x\to 0}\frac{\sin x}{-2\tan x(1+\tan^2 x)}\\
&= \lim_{x\to 0}\frac{\cos x}{-2(1+\tan^2 x)}\\
&= \frac{\cos 0}{-2(1+\tan 0)} = -\frac{1}{2}
\end{aligned}$$

ដូចនេះ $\lim\limits_{x\to 0}\dfrac{x-\sin x}{x-\tan x} = -\dfrac{1}{2}$

ខ) $\lim\limits_{x\to 0}\dfrac{x-\sin x}{x^3}$ រាងមិនកំណត់ $\dfrac{0}{0}$

តាមទ្រឹស្តីបទ L′Hospital យើងបាន

$$\begin{aligned}
\lim_{x\to 0}\frac{x-\sin x}{x^3} &= \lim_{x\to 0}\frac{(x-\sin x)'}{(x^3)'}\\
&= \lim_{x\to 0}\frac{1-\cos x}{3x^2}\\
&= \lim_{x\to 0}\frac{(1-\cos x)'}{(3x^2)'}\\
&= \lim_{x\to 0}\frac{\sin x}{6x} = \frac{1}{6}
\end{aligned}$$

ដូចនេះ $\lim\limits_{x\to 0}\dfrac{x-\sin x}{x^3} = \dfrac{1}{6}$

ជំពូក 2

ប្រធានលំហាត់

កម្រិតមូលដ្ឋាន

លំហាត់ ១
គណនាលីមីតខាងក្រោម

1. $\lim_{x\to 1}(x^3-2x^2+3x-3)$
2. $\lim_{x\to 1}\frac{4x-5}{5x-1}$
3. $\lim_{x\to 1}\frac{x^2-1}{x^2-3x+2}$
4. $\lim_{x\to 1}\frac{1-x^2}{x^2+2-3x}$
5. $\lim_{x\to 2}\frac{x-2}{x^2-6x+8}$
6. $\lim_{x\to 1}\frac{x^2-2x+1}{x^3-x}$
7. $\lim_{x\to 1}\left(\frac{1}{x-1}-\frac{2}{x^2-1}\right)$
8. $\lim_{x\to 1}\frac{x^2-5x+4}{x^3-1}$
9. $\lim_{x\to 1}\frac{2x-3+x^2}{x^3+2-x-2x^2}$
10. $\lim_{x\to -1}\frac{x^2-3x-4}{5x+5}$
11. $\lim_{x\to 2}\frac{x^3-8}{x-2}$
12. $\lim_{x\to 2}\frac{x^2-5x+6}{x^3-2x^2+4x-8}$
13. $\lim_{x\to 0}\frac{(2+x)^3-8}{x}$
14. $\lim_{x\to 0}\frac{\frac{1}{x+2}-\frac{1}{2}}{x}$
15. $\lim_{x\to a}\frac{x^3-a^3}{x-a}$ ចំពោះ $a\neq 0$
16. $\lim_{x\to 1}\frac{x^5+6x^3-5x-2}{x^4-5x^2+4}$

17. $\lim\limits_{x\to 1}\dfrac{x^3-x^2+x-1}{x-1}$

18. $\lim\limits_{x\to 1}\dfrac{x^5-1}{x^7-1}$

19. $\lim\limits_{x\to 3}\dfrac{\sqrt{x}-\sqrt{3}}{x-3}$

20. $\lim\limits_{x\to 1}\dfrac{\sqrt[3]{x}-1}{x-1}$

21. $\lim\limits_{x\to 1}\dfrac{\sqrt{x^2+x}-\sqrt{2}}{x^2-1}$

22. $\lim\limits_{x\to 1}\dfrac{\sin(x-1)}{x^2-3x+2}$

23. $\lim\limits_{x\to 0}\dfrac{\sqrt{1+x}-\cos x}{\sin x}$

24. $\lim\limits_{x\to 0}\dfrac{\tan x+2\sin x}{x-3\sin x}$

25. $\lim\limits_{x\to 0}\dfrac{2017\sin x-2018\tan x}{2019x-\sin x}$

26. $\lim\limits_{x\to 1}\dfrac{\sqrt[3]{x^2}-2\sqrt[3]{x}+1}{x-1}$

27. $\lim\limits_{x\to 1}\dfrac{\sqrt{x+3}-(x+1)}{x-1}$

28. $\lim\limits_{x\to 0}\dfrac{\sqrt{x+1}-1}{x}$

29. $\lim\limits_{x\to +\infty}\dfrac{-x^2+x+1}{3x^2-2x+1}$

30. $\lim\limits_{x\to +\infty}(x-\sqrt{x^2+1})$

31. $\lim\limits_{x\to -\infty}\dfrac{(x+2)(3x+4)(5-6x)}{(3x^2+2)(2x+1)}$

32. $\lim\limits_{x\to -2^+}\dfrac{x}{x+2}$

33. $\lim\limits_{x\to \frac{\pi}{2}^-}\tan x$

34. $\lim\limits_{x\to 1^-}\dfrac{x}{x-1}$

35. $\lim\limits_{x\to -\frac{\pi}{2}}\dfrac{\cos x}{x+\frac{\pi}{2}}$

36. $\lim\limits_{x\to \pi}\dfrac{\sin nx}{\sin x}$

37. $\lim\limits_{x\to \frac{\pi}{2}}(\pi-2x)\tan x$

38. $\lim\limits_{x\to 1}\dfrac{1+\cos\pi x}{(x-1)^2}$

39. $\lim\limits_{x\to \frac{\pi}{2}}\dfrac{(2x-\pi)\cos 3x}{\cos^2 x}$

40. $\lim\limits_{x\to \frac{\pi}{2}}\left(x\tan x-\dfrac{\pi}{2\cos x}\right)$

41. $\lim\limits_{x\to \frac{\pi}{3}}\left(\dfrac{x}{2}-\dfrac{\pi}{3}\cos x\right)\times\dfrac{1}{x-\frac{\pi}{3}}$

42. $\lim\limits_{x\to +\infty}\dfrac{1}{x-2}$

43. $\lim\limits_{x\to -\infty}\dfrac{1}{x^2-x}$

44. $\lim\limits_{x\to -\infty}\dfrac{x^2}{x^3+1}$

45. $\lim\limits_{x\to +\infty}\dfrac{x+2}{x^2}$

46. $\lim\limits_{x\to +\infty}\dfrac{x^2+5x-1}{x^2-3x+7}$

47. $\lim\limits_{x\to +\infty}\dfrac{x^2+5x+2}{x-1}$

48. $\lim\limits_{x\to +\infty}\dfrac{|x-1|}{\sqrt{x^2-3x+4}}$

49. $\lim\limits_{x\to +\infty}\dfrac{\sqrt{x^2+\sqrt{x^2+1}}}{x}$

50. $\lim\limits_{x\to+\infty}\dfrac{\sqrt{x+\sqrt{x+\sqrt{x}}}}{\sqrt{x+1}}$

51. $\lim\limits_{x\to-\infty}e^{x^2+1}$

52. $\lim\limits_{x\to+\infty}\dfrac{x+\ln x}{e^x}$

53. $\lim\limits_{x\to0}\dfrac{e^{2x}-3e^x+2}{e^x-1}$

54. $\lim\limits_{x\to0^+}(x\ln x+\ln x)$

55. $\lim\limits_{x\to+\infty}\dfrac{xe^x+x^2}{e^x+x^4}$

56. $\lim\limits_{x\to0}\dfrac{e^x+\sin x-1}{\tan x}$

57. $\lim\limits_{x\to1}\dfrac{\sqrt[n]{x}-1}{\sqrt[m]{x}-1}$

58. $\lim\limits_{x\to a}\dfrac{\sqrt{x-b}-\sqrt{a-b}}{x^2-a^2}$ ចំពោះ $a>0$ និង $b<0$

59. $\lim\limits_{x\to0}\dfrac{x^2-x\sin x}{x^2-\sin^2 x}$

60. $\lim\limits_{x\to0}\dfrac{2x-\sin x}{\frac{1-\cos x}{x}}$

61. $\lim\limits_{x\to+\infty}\ln\left(\dfrac{x}{x+1}\right)$

62. $\lim\limits_{x\to-\infty}\ln(e^x+1)$

63. $\lim\limits_{x\to+\infty}\ln(\ln x)$

64. $\lim\limits_{x\to+\infty}\dfrac{1}{e^x-1}$

65. $\lim\limits_{x\to+\infty}\left(\dfrac{xe^x+2}{x^2-2}\right)$

66. $\lim\limits_{x\to+\infty}\dfrac{x^4-5x}{x^2-3x+1}$

67. $\lim\limits_{x\to+\infty}\dfrac{\sqrt{x^2+1}+\sqrt{x}}{\sqrt[4]{x^3+x}-x^4}$

68. $\lim\limits_{x\to+\infty}\dfrac{(x+1)^{100}+(x+2)^{100}+\ldots+(x+100)^{100}}{x^{100}-10^{100}}$

69. $\lim\limits_{x\to0}\dfrac{\sqrt{x+2}-\sqrt{2}}{x}$

70. $\lim\limits_{x\to0}\dfrac{1-\cos x}{x^2}$

71. $\lim\limits_{x\to+\infty}\dfrac{3e^x+1}{5e^x+2}$

72. $\lim\limits_{x\to+\infty}\dfrac{\ln x}{x-1}$

73. $\lim\limits_{x\to0}\dfrac{2-\sqrt{x+4}}{x}$

74. $\lim\limits_{x\to1^+}\left(\dfrac{4}{1-\sqrt{x}}-\dfrac{1}{1-x}\right)$

75. $\lim\limits_{x\to0}\left(\dfrac{\sin 5x+x\sin 10x}{\sin 5x-x\sin 10x}\right)$

76. $\lim\limits_{x\to+\infty}\left(\dfrac{2e^x-x}{1+e^x}\right)$

77. $\lim\limits_{x\to\frac{\pi}{2}}\left(\dfrac{1-\sqrt{1-\cos x}}{\frac{\pi}{2}-x}\right)$

78. $\lim\limits_{x\to-1}\dfrac{1+x}{\sqrt{x^2+3}-2}$

79. $\lim\limits_{x\to+\infty}\dfrac{x^2-x+2}{(e^x+2)(e^x-1)}$

80. $\lim\limits_{x\to0}\dfrac{\sin x+e^x-1}{x^2+x}$

81. $\lim\limits_{x\to+\infty}\dfrac{\ln x+2}{x+1}$

82. $\lim_{x\to+\infty}\frac{e^x\ln x+1}{x^2}$

83. $\lim_{x\to\infty}\frac{e^x-1}{2e^x+5}$

84. $\lim_{x\to\frac{\pi}{3}}\frac{\sqrt{2\cos x}-1}{2\cos 2x+1}$

85. $\lim_{x\to 0}\frac{\frac{1}{(a+x)^3}-\frac{1}{a^3}}{x}$

86. $\lim_{x\to 0}\frac{\sqrt{x+3}-\sqrt{3}}{x}$

87. $\lim_{x\to\frac{\pi}{2}}\frac{\pi-2x}{\cos x}$

88. $\lim_{x\to\frac{\pi}{4}}\frac{2\sin\left(x-\frac{\pi}{4}\right)}{\frac{\pi}{4}-x}$

89. $\lim_{x\to 0}\frac{-2\sin 5x}{\sqrt{5}-\sqrt{x+5}}$

90. $\lim_{x\to 0}\frac{1-\cos^2 3x}{-2x^2}$

91. $\lim_{x\to 0}\frac{x^2-x}{|x|}$

92. $\lim_{x\to-\frac{\pi}{2}}\frac{\sin^2 x-1}{\sin x+1}$

93. $\lim_{x\to+\infty}\sqrt{x^4+x^2}-x^2$

94. $\lim_{x\to 0}\frac{(e^x+e^{-x})\sin^2 x}{2x^2}$

95. $\lim_{x\to 1}\frac{x-1}{\sqrt{x}-1}$

96. $\lim_{x\to 3}\frac{\sqrt{x+6}-3}{x^3-27}$

97. $\lim_{x\to 0}\frac{5\sin 5x}{x}$

98. $\lim_{x\to 0}\frac{\sqrt{1+x}-\sqrt{1-x}}{\sin x}$

99. $\lim_{x\to+\infty}(\sqrt{4x^2+1}-\sqrt{x^2-1})$

100. $\lim_{x\to\frac{\pi}{3}}\frac{\sqrt{3}\cos x-\sin x}{x-\frac{\pi}{3}}$

101. $\lim_{x\to 0}\frac{\cos 2x-1}{2x}$

102. $\lim_{x\to\frac{\pi}{2}}\frac{\cos\left(x-\frac{\pi}{2}\right)-1}{\frac{\pi}{2}-x}$

103. $\lim_{x\to 0}\frac{\cos^2 x-1}{x(\cos x+1)}$

104. $\lim_{x\to\frac{\pi}{2}}\frac{\sin^2 x-1}{1-\sin x}$

105. $\lim_{x\to 0}\frac{2\tan x+\sin x}{3x}$

106. $\lim_{x\to-\infty}\ln\left(\frac{x+1}{x+2}\right)$

107. $\lim_{x\to-2^-}\ln\left(\frac{x+1}{x+2}\right)$

108. $\lim_{x\to-1^+}\ln\left(\frac{x+1}{x+2}\right)$

109. $\lim_{x\to 0^+}(x-1)\ln x$

110. $\lim_{x\to+\infty}(x-1)\ln x$

លំហាត់ ២

កំណត់តម្លៃ a ដើម្បីឲ្យ $\lim_{x\to 0}\frac{1+ax-\sqrt{1+x}}{x}=\frac{1}{8}$ ។

លំហាត់ ៣
កំណត់ចំនួនពិត a និង b ដើម្បីឲ្យ $\lim_{x\to1}\frac{x^2+ax+b}{x-1}=5$ ។
លំហាត់ ៤
កំណត់ចំនួនពិត p និង q ដើម្បីឲ្យ $\lim_{x\to-2}\frac{x^2+px-6}{2x^2+3x-2}=q$ ។

កម្រិតមធ្យម

1. $\lim_{x\to0}\frac{\sqrt{x^2+1}-1}{\sqrt{x+1}-1}$
2. $\lim_{x\to0}\frac{\sqrt{x^2+1}-1}{\sqrt{x+1}-1}$
3. $\lim_{x\to1}\frac{x^{2017}+x-2}{x^2-1}$
4. $\lim_{x\to a}\frac{x^m-a^m}{x^n-a^n}$ ចំពោះ $m,n\in\mathbb{N}$
5. $\lim_{x\to1}\frac{x^3+x^2+x-3}{x^4+x^3+x^2+x-4}$
6. $\lim_{x\to1}\frac{x+x^2+x^3+\ldots+x^p-p}{x+x^2+x^3+\ldots+x^n-n}$
   ចំពោះ $p,n\in\mathbb{N}$
7. $\lim_{x\to1}\frac{nx^{n+1}-(n+1)x^n+1}{(x-1)^2}$
8. $\lim_{x\to0}\frac{\sqrt[m]{1+ax}-\sqrt[n]{1+bx}}{x}$
9. $\lim_{x\to0}\frac{\sqrt[m]{1+ax}-\sqrt[n]{1+bx}}{\sqrt[p]{1+cx}-\sqrt[q]{1+dx}}$
10. $\lim_{x\to0}\frac{\sin x+\sin2x+\ldots\sin nx}{x}$
11. $\lim_{x\to0}\frac{1-\cos x}{x\tan x}$
12. $\lim_{x\to\frac{\pi}{2}}\frac{\sin x}{x}$
13. $\lim_{x\to0}\frac{x-\sin x}{x^3}$
14. $\lim_{x\to0}\frac{x^2-\sin^2x}{x^4}$
15. $\lim_{x\to0}\frac{x-\sin x}{2x-\sin2x}$
16. $\lim_{x\to0}\frac{e^{ax}+\sin ax-1}{e^{bx}+\sin bx-1}$
17. $\lim_{x\to1}\frac{\sin^2(x^2-1)}{x^3-1}$
18. $\lim_{x\to0}\frac{\sin x\sin2x\sin3x\ldots\sin nx}{x^n}$
19. $\lim_{x\to0}\frac{\sin mx+\cos x-1}{\sin nx+\cos x-1}$
    ចំពោះ $m,n\in\mathbb{R}$
20. $\lim_{x\to0}\frac{(1+nx)^m-(1-mx)^n}{x^2}$
21. $\lim_{x\to0}\frac{\cos ax+\cos bx+\cos cx-3}{\cos dx+\cos ex+\cos fx-3}$
22. $\lim_{x\to0}\frac{1-x^2-\cos2x}{x^3+4x^2}$
23. $\lim_{x\to+\infty}x(\ln(x+1)-\ln x)$
24. $\lim_{x\to+\infty}(\sqrt{x^2+2x+1}+\sqrt{x^2+4x+1}+\ldots+\sqrt{x^2+2nx+1}-\sqrt{n^2x^2+1})$

25. $\lim_{n\to+\infty}\left(1-\frac{1}{2^2}\right)\left(1-\frac{1}{3^2}\right)\dots\left(1-\frac{1}{n^2}\right)$

26. $\lim_{x\to0}\frac{\tan x-\sin x}{x^3}$

27. $\lim_{x\to0}\frac{1-\cos x\cos 2x}{x^2}$

28. $\lim_{x\to0}\frac{x(a-b)}{\sin ax-\sin bx}$ ចំពោះ $a,b\neq 0$ និង $a\neq b$

29. $\lim_{x\to\frac{\pi}{6}}\frac{2\sin^2 x-3\sin x+1}{4\sin^2 x-1}$

30. $\lim_{x\to+\infty}(\sqrt{x^2+3x}-\sqrt{x^2+1}-1)$

31. $\lim_{x\to0}\frac{1-\cos x\sqrt{\cos 2x}}{x^2}$

32. $\lim_{x\to0}\frac{\sin^2 x}{\sqrt{1+\sin x}-\cos x}$

33. $\lim_{x\to+\infty}\frac{e^x-1}{x}$

34. $\lim_{x\to0^+}\frac{\ln x}{x}$

35. $\lim_{x\to0}\frac{\sqrt{x^2-x+1}-1}{\sqrt{1+x}-\sqrt{1-x}}$

36. $\lim_{x\to0}\frac{(1-\cos x)^2}{\tan^3 x-\sin^3 x}$

37. $\lim_{x\to0}\frac{\sqrt{2}-\sqrt{1+\cos x}}{\sin^2 x}$

38. $\lim_{x\to0}x\sin\frac{1}{x}$

39. $\lim_{x\to0}\frac{1+x\sin x-\cos 2x}{\sin^2 x}$

40. $\lim_{x\to0}\frac{\sin 3x}{\sqrt{x+1}-\sqrt[3]{x^2+1}}$

41. $\lim_{x\to0^+}x^x$

កម្រិតខ្ពស់

លំហាត់ ១

គេមានពហុកោណនិយ័តមួយមានរង្វាស់ជ្រុងស្មើនឹង n ចារឹកក្នុងរង្វង់មួយដែលមានរង្វាស់កាំស្មើនឹង a ។ យក S_n ជាក្រឡាផ្ទៃនៃពហុកោណនេះ ។ គណនា S_n និង $\lim_{n\to+\infty}S_n$ ។

លំហាត់ ២

គេឲ្យ $P(x)$ ជាពហុធាដែលមានមេគុណជាចំនួនវិជ្ជមាន ។ គណនា $\lim_{x\to+\infty}\frac{[P(x)]}{P([x])}$ ដែល $[x]$ តាងឲ្យផ្នែកគត់នៃ x ។

លំហាត់ ៣

គណនា

1. $\lim_{x\to0}x\cos\frac{1}{x}$

2. $\lim_{x\to0}x\left[\frac{1}{x}\right]$

3. $\lim_{x\to 0}\frac{x}{a}\left[\frac{b}{x}\right]$ ចំពោះ $a,b>0$

4. $\lim_{x\to 0}\frac{[x]}{x}$

5. $\lim_{x\to+\infty}x(\sqrt{x^2+1}-\sqrt{x^3+1})$

6. $\lim_{x\to 0}\frac{\cos\left(\frac{\pi}{2}\cos x\right)}{\sin(\sin x)}$

7. $\lim_{x\to+\infty}(\sqrt{x^4+2x^2+2}-x\sqrt[3]{x^3+x+1})$

8. $\lim_{x\to+\infty}(\sqrt{x^2+2x+3}+\sqrt{9x^2+10x+11}-\sqrt{16x^2+17x+18})$

9. $\lim_{x\to 0}x^2\left(1+2+3+\dots+\left[\frac{1}{|x|}\right]\right)$

10. $\lim_{x\to 0^+}x\left(\left[\frac{1}{x}\right]+\left[\frac{2}{x}\right]+\dots+\left[\frac{k}{x}\right]\right)$ ចំពោះ $k\in\mathbb{N}$

លំហាត់ ៤

1. ចំពោះ $a>b>0$ បង្ហាញថា $\frac{a-b}{a}<\ln\frac{a}{b}<\frac{a-b}{b}$ ។

2. បង្ហាញថា $\ln(x+1)>x-\frac{x^2}{2}$ ចំពោះគ្រប់ $x>0$ ។

3. គណនា $\lim_{x\to 0}\left[\frac{1}{\ln(x+1)}-\frac{1}{x}\right]$ ។

លំហាត់ ៥

ឧបមាថា $f:(-a,a)-\{0\}\to\mathbb{R}$ ។ បង្ហាញថា

ក) $\lim_{x\to 0}f(x)=l$ លុះត្រាតែ $\lim_{x\to 0}f(\sin x)=l$ ។

ខ) បើ $\lim_{x\to 0}f(x)=l$ នោះ $\lim_{x\to 0}f(|x|)=l$ ។ តើសំណើច្រាសនៃសំណើនេះពិតដែរ រឺទេ ?

លំហាត់ ៦

គេឲ្យអនុគមន៍ $f:(-a,a)-\{0\}\to(0,+\infty)$ និង បំពេញលក្ខខណ្ឌ $\lim_{x\to 0}\left[f(x)+\frac{1}{f(x)}\right]=2$ ។ បង្ហាញថា $\lim_{x\to 0}f(x)=1$ ។

1. គេមាន f ជាអនុគមន៍កំណត់លើ $(0,+\infty)$ដោយ $f(x)=\frac{x}{e^x-1}$ ។ គណនា $\lim\limits_{x\to 0} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។
2. គេមានស្ទីត u_n មួយកំណត់ដោយ $u_n=\frac{1}{n}\left[1+e^{\frac{1}{n}}+e^{\frac{2}{n}}+\ldots+e^{\frac{n-1}{n}}\right]$ ។ បង្ហាញថា $1+e^{\frac{1}{n}}+e^{\frac{2}{n}}+\ldots+e^{\frac{n-1}{n}}=\frac{1-e}{1-e^{\frac{1}{n}}}$ រួចទាញថា $u_n=(e-1)f\left(\frac{1}{n}\right)$ ។
3. តាមសំណួរ 2 ទាញរក $\lim\limits_{n\to+\infty} u_n$ ។

លំហាត់ ៨

គណនា $\lim\limits_{n\to+\infty}(\sqrt[3]{n^3+2n^2+1}-\sqrt[3]{n^3-1})$ ។

លំហាត់ ៩

គណនា $\lim\limits_{x\to-2}\frac{\sqrt[3]{5x+2}+2}{\sqrt{3x+10}-2}$ ។

លំហាត់ ១០

គេឲ្យ $\{a_n\}_{n\geq 1}$ ជាស្ទីតដែលបំពេញលក្ខខណ្ឌ $\sum\limits_{k=1}^{n} a_k=\frac{3n^2+9n}{2}$ ចំពោះគ្រប់ $n\geq 1$ ។ បង្ហាញថា $\{a_n\}$ ជាស្ទីតនព្វន្ត រួចគណនា $\lim\limits_{n\to+\infty}\frac{1}{na_n}\sum\limits_{k=1}^{n} a_k$ ។

លំហាត់ ១១

គេឲ្យស្ទីត a_n កំណត់ដោយ $a_1=a_2=0$ និង $a_{n+1}=\frac{1}{3}(a_n+a_{n-1}^2+b)$ ដែល $0\leq b<1$ ។ បង្ហាញថា a_n ជាស្ទីតរួម និង គណនា $\lim\limits_{n\to+\infty} a_n$ ។

លំហាត់ ១២

គេឲ្យស្ទីតចំនួនពិត $\{x_n\}$ កំណត់ដោយ $x_1=1$ និង $x_n=2x_{n-1}+\frac{1}{2}$ ចំពោះគ្រប់ $n\geq 2$ ។ គណនា $\lim\limits_{n\to+\infty} x_n$ ។

លំហាត់ ១៣

គណនា $\lim\limits_{n\to+\infty}\left[n\left(\frac{4}{5}\right)^n+n^2\sin^n\frac{\pi}{6}+\cos\left(2n\pi+\frac{\pi}{n}\right)\right]$ ។

លំហាត់ ១៤

គណនា $\lim\limits_{n\to+\infty}\sum\limits_{k=1}^{n}\frac{k!k}{(n+1)!}$ ។

លំហាត់ ១៥

គណនា $\lim\limits_{n\to+\infty}\sqrt[n]{\frac{3^{3n}(n!)^3}{(3n)!}}$ ។

លំហាត់ ១៦

គេឲ្យស្វ៊ីតនៃចំនួនពិតវិជ្ជមាន $\{x_n\}$ ដែល $(n+1)x_{n+1}-nx_n<0$ ចំពោះគ្រប់ $n\geq 1$ ។ បង្ហាញថា $\{x_n\}$ ជាស្វ៊ីតរួម និង គណនាលីមីតរបស់វា ។

លំហាត់ ១៧

រកតម្លៃ a និង b ដើម្បីឲ្យ $\lim\limits_{n\to+\infty}(\sqrt[3]{1-n^3}-an-b)=0$ ។

លំហាត់ ១៨

គេឲ្យ $p\in\mathbb{N}$ និង $\alpha_1,\alpha_2,...,\alpha_p$ ជា p ចំនួនពិតវិជ្ជមានផ្សេងគ្នា ។

គណនា $\lim\limits_{n\to+\infty}\sqrt[n]{\alpha_1^n+\alpha_2^n+...+\alpha_p^n}$ ។

លំហាត់ ១៩

ចំពោះ $a\in\mathbb{R}^*$ គណនា $\lim\limits_{x\to-a}\dfrac{\cos x-\cos a}{x^2-a^2}$ ។

លំហាត់ ២០

ចំពោះ $n\in\mathbb{N}^*$ គណនា $\lim\limits_{x\to0}\dfrac{\ln(1+x+x^2+...+x^n)}{nx}$ ។

លំហាត់ ២១

គណនា $\lim\limits_{n\to+\infty}\left(n^2+n-\sum\limits_{k=1}^{n}\dfrac{2k^3+8k^2+6k-1}{k^2+4k+3}\right)$ ។

លំហាត់ ២២

កំណត់ $a\in\mathbb{R}^*$ ដែលបំពេញលក្ខខណ្ឌ $\lim\limits_{x\to0}\dfrac{1-\cos ax}{x^2}=\lim\limits_{x\to\pi}\dfrac{\sin x}{\pi-x}$ ។

លំហាត់ ២៣

គណនា $\lim\limits_{x\to1}\dfrac{\sqrt[3]{x^2+7}-\sqrt{x+3}}{x^2-3x+2}$ ។

លំហាត់ ២៤

គណនា $\lim\limits_{n\to+\infty}(\sqrt{2n^2+n}-\lambda\sqrt{2n^2-n})$ ។

លំហាត់ ២៥

គេឲ្យ $a,b,c\in\mathbb{R}$ ។ គណនា $\lim\limits_{x\to+\infty}(a\sqrt{x+1}+b\sqrt{x+2}+c\sqrt{x+3})$ ។

លំហាត់ ២៦

កំណត់សំណុំ A ដែល $A\subset\mathbb{R}$ ដើម្បីឲ្យ $ax^2+x+3\geq0$ ចំពោះ $\forall a\in A$ និង $\forall x\in\mathbb{R}$ ។

ចំពោះគ្រប់ $a\in A$ គណនា $\lim\limits_{x\to+\infty}(x+1-\sqrt{ax^2+x+3})$ ។

លំហាត់ ២៧

ចំពោះ $k\in\mathbb{R}$ គណនា $\lim\limits_{n\to+\infty}n^k\left(\sqrt{\dfrac{n}{n+1}}-\sqrt{\dfrac{n+2}{n+3}}\right)$ ។

លំហាត់ ២៨

គេឲ្យ $k\in\mathbb{N}$ និង $a\in\mathbb{R}_+\setminus\{1\}$ ។

គណនា $\lim_{n\to+\infty} n^k(a^{\frac{1}{n}}-1)\left(\sqrt{\frac{n-1}{n}}-\sqrt{\frac{n+1}{n+2}}\right)$ ។

លំហាត់ ២៩

គណនា $\lim_{n\to+\infty}\sum_{k=1}^{n}\frac{1}{\sqrt{n^2+k}}$ ។

លំហាត់ ៣០

គេឲ្យ $a>0, p\geq 2$ ។ គណនា $\lim_{n\to+\infty}\sum_{k=1}^{n}\frac{1}{\sqrt[p]{n^p+ka}}$ ។

លំហាត់ ៣១

គណនា $\lim_{n\to+\infty}\frac{n!}{(1+1^2)(1+2^2)...(1+n^2)}$ ។

លំហាត់ ៣២

គណនា $\lim_{n\to+\infty}\left(\frac{2n^2-3}{2n^2-n+1}\right)^{\frac{n^2-1}{n}}$ ។

លំហាត់ ៣៣

គណនា $\lim_{x\to 0}\frac{\sqrt{1+\sin^2 x}-\cos x}{1-\sqrt{1+\tan^2 x}}$ ។

លំហាត់ ៣៤

គណនា $\lim_{x\to+\infty}\left(\frac{x+\sqrt{x}}{x-\sqrt{x}}\right)^x$ ។

លំហាត់ ៣៥

គណនា $\lim_{x\to 0^+}(\cos x)^{\frac{1}{\sin x}}$ ។

លំហាត់ ៣៦

គណនា $\lim_{x\to 0}(e^x+\sin x)^{\frac{1}{x}}$ ។

លំហាត់ ៣៧

គេឲ្យ $a,b\in\mathbb{R}_+$ ។ គណនា $\lim_{n\to+\infty}\left(\frac{a-1+\sqrt[n]{b}}{a}\right)^n$ ។

លំហាត់ ៣៨

គេឲ្យស្វ៊ីត (a_n) កំណត់ដោយ $a_n=\begin{cases}1 \text{ បើ } n\leq k, k\in\mathbb{N}^* \\ \frac{(n+1)^k-n^k}{C_n^{k-1}} \text{ បើ } n>k\end{cases}$

ក) គណនា $\lim_{n\to+\infty} a_n$

ខ) បើ $b_n=1+\sum_{k=1}^{n} k\lim_{n\to+\infty} a_n$ គណនា $\lim_{n\to+\infty}\left(\frac{b_n^2}{b_{n-1}b_{n+1}}\right)^n$ ។

លំហាត់ ៣៩

គេឲ្យ (x_n) ជាស៊ីតនៃចំនួនពិតដែលបំពេញលក្ខខណ្ឌ $x_{n+2}=\dfrac{x_{n+1}+x_n}{2}$ ចំពោះគ្រប់ $n\in\mathbb{N}^*$ ។ បើ $x_1\le x_2$
ក) បង្ហាញថា (x_{2n+1}) ជាស៊ីតកើន ហើយ (x_{2n}) ជាស៊ីតចុះ
ខ) បង្ហាញថា $|x_{n+2}-x_{n+1}|=\dfrac{x_2-x_1}{2^n}$ ចំពោះគ្រប់ $n\in\mathbb{N}^*$
គ) បង្ហាញថា $2x_{n+2}+x_{n+1}=2x_2+x_1$ ចំពោះគ្រប់ $n\in\mathbb{N}^*$
ឃ) បង្ហាញថា (x_n) ជាស៊ីតរួម ហើយមានលីមីត $\dfrac{x_1+2x_2}{3}$ ។

លំហាត់ ៤០

គេឲ្យ $a_n,b_n\in\mathbb{Q}$ ដែលបំពេញលក្ខខណ្ឌ $(1+\sqrt{2})^n=a_n+b_n\sqrt{2}$ ចំពោះគ្រប់ $n\in\mathbb{N}^*$ ។ គណនា $\lim\limits_{n\to+\infty}\dfrac{a_n}{b_n}$ ។

លំហាត់ ៤១

គេឲ្យ $a>0$ ។ គណនា $\lim\limits_{x\to 0}\dfrac{(a+x)^x-1}{x}$ ។

លំហាត់ ៤២

គេឲ្យ $|a_1\sin x+a_2\sin 2x+\ldots+a_n\sin nx|\le|\sin x|$ ចំពោះគ្រប់ $x\in\mathbb{R}$ ។ បង្ហាញថា $|a_1+2a_2+\ldots+na_n|\le 1$ ។

លំហាត់ ៤៣

ឧបមាថា f និង g ជាអនុគមន៍មានដេរីវេត្រង់ $x=a$ ។ គណនា
ក) $\lim\limits_{x\to a}\dfrac{xf(a)-af(x)}{x-a}$
ខ) $\lim\limits_{x\to a}\dfrac{f(x)g(a)-f(a)g(x)}{x-a}$ ។

លំហាត់ ៤៤

គេឲ្យ f ជាអនុគមន៍មានឌីផេរ៉ង់ស្យែលត្រង់ $x=a$ ។ គណនា
ក) $\lim\limits_{x\to a}\dfrac{a^nf(x)-x^nf(a)}{x-a}$
ខ) $\lim\limits_{x\to a}\dfrac{f(x)e^x-f(a)}{f(x)\cos x-f(a)}$ ចំពោះ $a=0$ និង $f'(0)\neq 0$
គ) $\lim\limits_{n\to+\infty}n\left[f\left(1+\dfrac{1}{n}\right)+f\left(1+\dfrac{2}{n}\right)+\ldots+f\left(1+\dfrac{k}{n}\right)-kf(a)\right]$
ឃ) $\lim\limits_{n\to+\infty}n\left[f\left(1+\dfrac{1}{n^2}\right)+f\left(1+\dfrac{2}{n^2}\right)+\ldots+f\left(1+\dfrac{n}{n^2}\right)-nf(a)\right]$ ។

លំហាត់ ៤៥

គេឲ្យស៊ីត (a_n) កំណត់ដោយ $a_1=\dfrac{3}{2}$ និង $a_{n+1}=\dfrac{a_n^2-a_n+1}{a_n}$ ។ បង្ហាញថា (a_n) ជាស៊ីតរួម និង គណនាលីមីតរបស់វា ។

លំហាត់ ៤៦

គេឲ្យស្ទីត (x_n) មួយកំណត់ដោយ $x_0 \in (0,1)$ និង $x_{n+1} = x_n - x_n^2 + x_n^3 - x_n^4$ ចំពោះគ្រប់ $n \geq 0$ ។ បង្ហាញថា (x_n) គឺជាស្ទីតរួម និង គណនាលីមីតរបស់វា ។

លំហាត់ ៤៧

គេឲ្យ $a > 0$ និង $b \in (a,2a)$ ។ យក (x_n) ជាស្ទីតកំណត់ដោយ $x_0 = b$ និង $x_{n+1} = a + \sqrt{x_n(2a - x_n)}$ ចំពោះគ្រប់ $n \geq 0$ ។ សិក្សាភាពរួមនៃ (x_n) ។

លំហាត់ ៤៨

គណនា $\lim\limits_{n\to+\infty} \sum\limits_{k=1}^{n} \frac{k}{4k^4+1}$ ។

លំហាត់ ៤៩

គណនា $\lim\limits_{n\to+\infty} \left(n+1 - \sum\limits_{i=2}^{n} \sum\limits_{k=2}^{i} \frac{k-1}{k!} \right)$ ។

លំហាត់ ៥០

គណនា $\lim\limits_{n\to+\infty} \frac{1^1 + 2^2 + 3^3 + \ldots + n^n}{n^n}$ ។

លំហាត់ ៥១

គេឲ្យស្ទីត (a_n) កំណត់ដោយ $a_0 = 1$ និង $a_{n-1} - a_n = \frac{n}{(n+1)!}$ ចំពោះ $n \geq 1$ ។ គណនា $\lim\limits_{n\to+\infty} (n+1)! \ln a_n$ ។

លំហាត់ ៥២

គេឲ្យស្ទីតចំនួនពិត (x_n) កំណត់ដោយ $x_1 = a > 0$ និង $x_{n+1} = \frac{x_1 + 2x_2 + 3x_3 + \ldots + nx_n}{n}$ ចំពោះ $n \in \mathbb{N}$ ។ គណនា $\lim\limits_{n\to+\infty} x_n$ ។

លំហាត់ ៥៣

គេឲ្យ $n \in \mathbb{N}$ ។ គណនា $\lim\limits_{x\to0} \frac{1 - \cos x \cos 2x \ldots \cos nx}{x^2}$ ។

លំហាត់ ៥៤

គេឲ្យ f ជាអនុគមន៍កំណត់ដោយ $f(0) = 0$ និង មានឌីផេរ៉ង់ស្យែលត្រង់ 0 ។ ចំពោះ $k \in \mathbb{N}$ គណនា $\lim\limits_{x\to0} \frac{1}{x} \left[f(x) + f\left(\frac{x}{2}\right) + f\left(\frac{x}{3}\right) + \ldots + f\left(\frac{x}{k}\right) \right]$ ។

លំហាត់ ៥៥

គេឲ្យ $k,m \in \mathbb{N}$ ។ គណនា

ក) $\lim\limits_{n\to+\infty} \frac{(n+1)^m + (n+2)^m + \ldots + (n+k)^m}{n^{m-1}} - kn$

ខ) $\lim\limits_{n\to+\infty} \frac{\left(a+\frac{1}{n}\right)^n \left(a+\frac{2}{n}\right)^n \ldots \left(a+\frac{k}{n}\right)^n}{a^{nk}}$

គ) $\lim\limits_{n\to+\infty} \left(1+\frac{a}{n^2}\right)\left(1+\frac{2a}{n^2}\right)\ldots\left(1+\frac{na}{n^2}\right)$ ។

លំហាត់ ៥៦
ឧបមាថា f ជាអនុគមន៍មានឌីផេរ៉ង់ស្យែលត្រង់ a ហើយ (x_n) និង (z_n) ជាស្ទីតរួមទៅរក a ដែល $x_n < a < z_n$ ចំពោះគ្រប់ $n \in \mathbb{N}$ ។ បង្ហាញថា $\lim\limits_{n\to+\infty} \dfrac{f(x_n)-f(z_n)}{x_n - z_n} = f'(a)$ ។

លំហាត់ ៥៧
គេឲ្យ f ជាអនុគមន៍ជាប់លើចន្លោះបិទ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើចន្លោះបើក (a,b) ។ បើគេដឹងថា $f(a)=f(b)=0$ បង្ហាញថា មាន $\alpha \in (a,b)$ ដែល $\alpha f(x)+f'(x)=0$ ។

លំហាត់ ៥៨
គេឲ្យ f និង g ជាអនុគមន៍ជាប់លើចន្លោះបិទ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើចន្លោះបើក (a,b) ។ បើគេដឹងថា $f(a)=f(b)=0$ បង្ហាញថា មាន $x\in(a,b)$ ដែល $g'(x)f(x)+f'(x)=0$ ។

លំហាត់ ៥៩
គេឲ្យ f ជាអនុគមន៍ជាប់លើចន្លោះបិទ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើចន្លោះបើក (a,b) ។ ឧបមាថា $\dfrac{f(a)}{a}=\dfrac{f(b)}{b}$ បង្ហាញថា មាន $x\in(a,b)$ ដែល $xf'(x)=f(x)$ ។

លំហាត់ ៦០
គេឲ្យ f ជាអនុគមន៍ជាប់លើចន្លោះបិទ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើចន្លោះបើក (a,b) ។ បើគេដឹងថា $f^2(b)-f^2(a)=b^2-a^2$ បង្ហាញថា សមីការ $f'(x)f(x)=x$ មានរឹសមួយយ៉ាងតិចនៅលើចន្លោះ (a,b) ។

លំហាត់ ៦១
គេឲ្យ f ជាអនុគមន៍ជាប់ និង មិនសូន្យលើ $[a,b]$ ហើយមានឌីផេរ៉ង់ស្យែលលើ (a,b) ។ បើគេដឹងថា $f(a)g(b)=f(b)g(a)$ បង្ហាញថា មាន $x\in(a,b)$ ដែល $\dfrac{f'(x)}{f(x)}=\dfrac{g'(x)}{g(x)}$ ។

លំហាត់ ៦២
គណនា

ក) $\lim\limits_{n\to+\infty}\left(\dfrac{1^k+2^k+\dots+n^k}{n^{k+1}}\right)$

ខ) $\lim\limits_{n\to+\infty}\left(\dfrac{1}{n+1}+\dfrac{1}{n+2}+\dots+\dfrac{1}{n+n}\right)$

គ) $\lim\limits_{n\to+\infty}\left(\dfrac{n}{n^2+1}+\dfrac{n}{n^2+4}+\dfrac{n}{n^2+9}+\dots+\dfrac{n}{n^2+n^2}\right)$

លំហាត់ ៦៣
ឧបមាថា $a_0,a_1,\dots,a_n$ ជាចំនួនពិតវិជ្ជមានដែលបំពេញលក្ខខណ្ឌ $\dfrac{a_0}{n+1}+\dfrac{a_1}{n}+\dots+\dfrac{a_{n-1}}{2}+a_n=0$ ។ បង្ហាញថា ពហុធា $P(x)=a_0x^n+a_1x^{n-1}+\dots+a_n$ មានរឹសយ៉ាងហោចណាស់មួយលើចន្លោះ $(0,1)$ ។

លំហាត់ ៦៤
ចំពោះ $a_0,a_1,\dots,a_n$ ជាចំនួនពិតដែលបំពេញលក្ខខណ្ឌ

$\frac{a_0}{1}+\frac{2a_1}{2}+\frac{2^2a_2}{3}+...+\frac{2^{n-1}a_{n-1}}{n}+\frac{2^na_n}{n+1}=0$ ។
បង្ហាញថា អនុគមន៍ $f(x)=a_n\ln^n x+a_{n-1}\ln^{n-1}x+...+a_1\ln x+a_0$ មានរឹសយ៉ាងហោចណាស់មួយលើ $(1,e^2)$ ។

លំហាត់ ៦៥

គេឲ្យ $P(x)$ ជាពហុធាដែលមានដឺក្រេ $n,n\geq 2$ ។ បង្ហាញថា បើ $P(x)$ មានរឹសទាំងអស់ជាចំនួនពិត នោះ $P'(x)$ ក៏មានរឹសទាំងអស់ជាចំនួនពិតដែរ ។

លំហាត់ ៦៦

គេឲ្យ f ជាអនុគមន៍ជាប់ និង មានឌីផេរ៉ង់ស្យែលលើ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលំដាប់ ២ លើ (a,b) ។ ឧបមាថា $f(a)=f'(a)=f(b)=0$ បង្ហាញថា មាន $x_1\in(a,b)$ ដែល $f'(x_1)=0$ ។

លំហាត់ ៦៧

គេឲ្យ f ជាអនុគមន៍ជាប់ និង មានឌីផេរ៉ង់ស្យែលលើចន្លោះ $[a,b]$ ហើយ មានឌីផេរ៉ង់ស្យែលលំដាប់ ២ លើចន្លោះ (a,b) ។ ឧបមាថា $f(a)=f(b)$ និង $f'(a)=f'(b)=0$ បង្ហាញថា មាន $x_1,x_2\in(a,b)$ ដែល $x_1\neq x_2$ និង $f''(x_1)=f''(x_2)$ ។

លំហាត់ ៦៨

បង្ហាញថា សមីការ

ក) $x^{13}+7x^3-5=0$

ខ) $3^x+4^x=5^x$ មានរឹសជាចំនួនពិតតែមួយគត់ ។

លំហាត់ ៦៩

ចំពោះចំនួនពិតមិនសូន្យ $a_1,a_2,...,a_n$ និង n ចំនួនពិតផ្សេងគ្នា $\alpha_1,\alpha_2,...,\alpha_n$ បង្ហាញថា សមីការ $a_1x^{\alpha_1}+a_2x^{\alpha_2}+...+a_nx^{\alpha_n}=0$ មានរឹសជាចំនួនពិតយ៉ាងច្រើន $n-1$ លើ $(0,+\infty)$ ។

លំហាត់ ៧០

ចំពោះ f,g និង h ជាអនុគមន៍ជាប់លើ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើ (a,b) គេកំណត់អនុគមន៍ F ដោយ $F(x)=\begin{vmatrix} f(x) & g(x) & h(x)\\ f(a) & g(a) & h(a)\\ f(b) & g(b) & h(b)\end{vmatrix}$ ចំពោះ $x\in[a,b]$។
បង្ហាញថា $\exists x_0\in(a,b)$ ដែល $f'(x_0)=0$ រួចទាញបញ្ជាក់ទ្រឹស្តីបទតម្លៃមធ្យម និង ទ្រឹស្តីបទ Cauchy ។

លំហាត់ ៧១

គេឲ្យ f ជាអនុគមន៍ជាប់លើ $[0,2]$ និង មានឌីផេរ៉ង់ស្យែលលើ $(0,2)$ ។ បើគេដឹងថា $f(0)=0, f(1)=1$ និង $f(2)=2$ បង្ហាញថា $\exists x_0\in(0,2)$ ដែល $f''(x_0)=0$ ។

លំហាត់ ៧២

គេឲ្យ f ជាអនុគមន៍ជាប់លើ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើ (a,b) ។ បើ f មិនមែនជាអនុគមន៍លីនេអ៊ែរ បង្ហាញថា $\exists x_1,x_2\in(a,b)$ ដែល $f'(x_1)<\frac{f(b)-f(a)}{b-a}<f'(x_2)$ ។

លំហាត់ ៧៣

គេឲ្យ f ជាអនុគមន៍ជាប់លើ $[0,1]$ និង មានឌីផេរ៉ង់ស្យែលលើ $(0,1)$ ។ ឧបមាថា $f(0)=f(1)=0$ និង មាន $x_0 \in (0,1)$ ដែល $f(x_0)=1$ បង្ហាញថា $\exists c \in (0,1)|f'(c)| > 2$ ។

ជំពូក 3

ដំណោះស្រាយ

កម្រិតមូលដ្ឋាន

លំហាត់ ១
គណនាលីមីតខាងក្រោម

1. $\lim_{x\to 1}(x^3-2x^2+3x-3)$
   យើងមាន $\lim_{x\to 1}(x^3-2x^2+3x-3) = 1^3-2(1^2)+3(1)-3 = 1-2+3-3 = -1$
   ដូចនេះ $\lim_{x\to 1}(x^3-2x^2+3x-3) = -1$

2. $\lim_{x\to 1}\frac{4x-5}{5x-1}$
   យើងមាន $\lim_{x\to 1}\frac{4x-5}{5x-1} = \frac{4(1)-5}{5(1)-1} = \frac{-1}{4} = -\frac{1}{4}$
   ដូចនេះ $\lim_{x\to 1}\frac{4x-5}{5x-1} = -\frac{1}{4}$

3. $\lim_{x\to 1}\frac{x^2-1}{x^2-3x+2}$ មានរាងមិនកំណត់ $\frac{0}{0}$

យើងមាន

$$\begin{aligned}\lim_{x\to1}\frac{x^2-1}{x^2-3x+2}&=\lim_{x\to1}\frac{(x-1)(x+1)}{(x-1)(x-2)}\\&=\lim_{x\to1}\frac{x+1}{x-2}\\&=\frac{1+1}{1-2}=\frac{2}{-1}=-2\end{aligned}$$

ដូចនេះ $\lim_{x\to1}\frac{x^2-1}{x^2-3x+2}=-2$

4. $\lim_{x\to1}\frac{1-x^2}{x^2+2-3x}$ មានរាងមិនកំណត់ $\frac{0}{0}$
យើងមាន

$$\begin{aligned}\lim_{x\to1}\frac{1-x^2}{x^2+2-3x}&=\lim_{x\to1}\frac{-(x^2-1)}{x^2-3x+2}\\&=\lim_{x\to1}\frac{-(x-1)(x+1)}{(x-1)(x-2)}\\&=\lim_{x\to1}\frac{-(x+1)}{x-2}\end{aligned}$$

$$=\frac{-(1+1)}{1-2}=\frac{-2}{-1}=2$$

ដូចនេះ $\lim_{x\to1}\frac{1-x^2}{x^2+2-3x}=2$

5. $\lim_{x\to2}\frac{x-2}{x^2-6x+8}$ មានរាងមិនកំណត់ $\frac{0}{0}$
យើងមាន

$$\begin{aligned}\lim_{x\to2}\frac{x-2}{x^2-6x+8}&=\lim_{x\to2}\frac{x-2}{(x-2)(x-4)}\\&=\lim_{x\to2}\frac{1}{x-4}\\&=\frac{1}{2-4}=-\frac{1}{2}\end{aligned}$$

ដូចនេះ $\lim_{x\to2}\frac{x-2}{x^2-6x+8}=-\frac{1}{2}$

6. $\lim\limits_{x\to 1}\dfrac{x^2-2x+1}{x^3-x}$ មានរាងមិនកំណត់ $\dfrac{0}{0}$
យើងមាន

$$\begin{aligned}\lim_{x\to 1}\frac{x^2-2x+1}{x^3-x} &= \lim_{x\to 1}\frac{(x-1)^2}{x(x^2-1)}\\ &= \lim_{x\to 1}\frac{(x-1)^2}{x(x-1)(x+1)}\\ &= \lim_{x\to 1}\frac{(x-1)}{x(x+1)}\\ &= \frac{1-1}{(1)(1+1)} = \frac{0}{2} = 0\end{aligned}$$

ដូចនេះ $\lim\limits_{x\to 1}\dfrac{x^2-2x+1}{x^3-x} = 0$

7. $\lim\limits_{x\to 1}\left(\dfrac{1}{x-1}-\dfrac{2}{x^2-1}\right)$ មានរាងមិនកំណត់ $\infty-\infty$
យើងមាន

$$\begin{aligned}\lim_{x\to0^+}(\cos x)^{\frac{1}{\sin x}} &= \lim_{x\to0^+}\left[(1+(\cos x-1))^{\frac{1}{\cos x-1}}\right]^{\frac{\cos x-1}{\sin x}}\\ &= e^{\lim_{x\to0^+}\frac{-2\sin^2\frac{x}{2}}{2\sin\frac{x}{2}\cos\frac{x}{2}}}\\ &= e^{\lim_{x\to0^+}-\tan\frac{x}{2}}\\ &= e^0=1\end{aligned}$$

ដូចនេះ $\lim\limits_{x\to0^+}(\cos x)^{\frac{1}{\sin x}}=1$

លំហាត់ ៣៦

គណនា $\lim\limits_{x\to0}(e^x+\sin x)^{\frac{1}{x}}$ ។

ចម្លើយ

យើងមាន

$$\begin{aligned}\lim_{x\to 0}(e^x+\sin x)^{\frac{1}{x}} &= \lim_{x\to 0}\left[e^x\left(1+\frac{\sin x}{e^x}\right)\right]^{\frac{1}{x}}\\ &= \lim_{x\to 0}(e^x)^{\frac{1}{x}}\times\lim_{x\to 0}\left[\left(1+\frac{\sin x}{e^x}\right)^{\frac{e^x}{\sin x}}\right]^{\frac{\sin x}{xe^x}}\\ &= e\times e^{\lim_{x\to 0}\frac{\sin x}{x}\times\frac{1}{e^x}} = e^2\end{aligned}$$

លំហាត់ ៣៧

គេឲ្យ $a,b\in\mathbb{R}_+$ ។ គណនា $\lim_{n\to+\infty}\left(\frac{a-1+\sqrt[n]{b}}{a}\right)^n$ ។

សម្រាយ

យើងមាន

$$\begin{aligned}\lim_{n\to+\infty}\left(\frac{a-1+\sqrt[n]{b}}{a}\right)^n &= \lim_{n\to+\infty}\left[\left(1+\frac{\sqrt[n]{b}-1}{a}\right)^{\frac{a}{\sqrt[n]{b}-1}}\right]^{\frac{n(\sqrt[n]{b}-1)}{a}}\\ &= e^{\frac{1}{a}\lim_{n\to+\infty}\frac{b^{\frac{1}{n}}-1}{\frac{1}{n}}}\\ &= e^{\frac{\ln b}{a}} = b^{\frac{1}{a}}\end{aligned}$$

ដូចនេះ $\lim_{n\to+\infty}\left(\frac{a-1+\sqrt[n]{b}}{a}\right)^n = b^{\frac{1}{a}}$

លំហាត់ ៣៨

គេឲ្យស្វ៊ីត (a_n) កំណត់ដោយ $a_n=\begin{cases}1\text{បើ}n\le k, k\in\mathbb{N}^*\\ \dfrac{(n+1)^k-n^k}{C_n^{k-1}}\text{បើ}n>k\end{cases}$

ក) គណនា $\lim_{n\to+\infty}a_n$

ខ) បើ $b_n=1+\sum_{k=1}^{n}k\lim_{n\to+\infty}a_n$ គណនា $\lim_{n\to+\infty}\left(\frac{b_n^2}{b_{n-1}b_{n+1}}\right)^n$ ។

ចម្លើយ

ក) គណនា $\lim_{n\to+\infty}a_n$

យើងមាន

$$\begin{aligned}
\lim_{n\to+\infty} a_n &= \lim_{n\to+\infty} \frac{(n+1)^k - n^k}{C_n^{k-1}} \\
&= \lim_{n\to+\infty} \frac{n^k C_k^0 + n^{k-1}C_k^1 + ... + nC_k^{k-1} + 1 - n^k}{C_n^{k-1}} \\
&= \lim_{n\to+\infty} \frac{n^k + n^{k-1}C_k^1 + ... + nC_k^{k-1} + 1 - n^k}{\frac{n!}{(k-1)![n-(k-1)]!}} \\
&= \lim_{n\to+\infty} \frac{n^{k-1}C_k^1 + ... + nC_k^{k-1} + 1}{\frac{n(n-1)(n-2)...[n-(k-2)]}{(k-1)!}} \\
&= (k-1)! \lim_{n\to+\infty} \frac{n^{k-1}C_k^1 + ... + nC_k^{k-1} + 1}{n^{k-1}\left(1-\frac{1}{n}\right)\left(1-\frac{2}{n}\right)...\left(1-\frac{k-2}{n}\right)} \\
&= (k-1)!C_k^1 \\
&= (k-1)! \times \frac{k!}{(k-1)!} = k!
\end{aligned}$$

ដូចនេះ $\lim\limits_{n\to+\infty} a_n = k!$

ខ) យើងមាន

$$\begin{aligned}
b_n &= 1 + \sum_{k=1}^{n} k \lim_{n\to+\infty} a_n \\
&= 1 + \sum_{k=1}^{n} kk! \\
&= 1 + \sum_{k=1}^{n} [(k+1)! - k!] \\
&= 1 + (n+1)! - 1 = (n+1)!
\end{aligned}$$

នោះ

$$\begin{aligned}\lim_{n\to+\infty}\left(\frac{b_n^2}{b_{n-1}b_{n+1}}\right)^n &= \lim_{n\to+\infty}\left[\frac{(n+1)!\,(n+1)!}{n!\,(n+2)!}\right]^n\\ &= \lim_{n\to+\infty}\left(\frac{n+1}{n+2}\right)^n\\ &= \lim_{n\to+\infty}\left[\left(1-\frac{1}{n+2}\right)^{-(n+2)}\right]^{-\frac{n}{n+2}}\\ &= e^{-1}=\frac{1}{e}\end{aligned}$$

ដូចនេះ $\lim\limits_{n\to+\infty}\left(\frac{b_n^2}{b_{n-1}b_{n+1}}\right)^n=\frac{1}{e}$

លំហាត់ ៣៩

គេឲ្យ (x_n) ជាស្វ៊ីតនៃចំនួនពិតដែលបំពេញលក្ខខណ្ឌ $x_{n+2}=\frac{x_{n+1}+x_n}{2}$ ចំពោះគ្រប់ $n\in\mathbb{N}^*$ ។ បើ $x_1\le x_2$

ក) បង្ហាញថា (x_{2n+1}) ជាស្វ៊ីតកើន ហើយ (x_{2n}) ជាស្វ៊ីតចុះ

ខ) បង្ហាញថា $|x_{n+2}-x_{n+1}|=\frac{x_2-x_1}{2^n}$ ចំពោះគ្រប់ $n\in\mathbb{N}^*$

គ) បង្ហាញថា $2x_{n+2}+x_{n+1}=2x_2+x_1$ ចំពោះគ្រប់ $n\in\mathbb{N}^*$

ឃ) បង្ហាញថា (x_n) ជាស្វ៊ីតរួម ហើយមានលីមីត $\frac{x_1+2x_2}{3}$ ។

សម្រាយ

ក) បង្ហាញថា (x_{2n+1}) ជាស្វ៊ីតកើន ហើយ (x_{2n}) ជាស្វ៊ីតចុះ

យើងមាន $x_1\le x_2$

ឧបមាថា $x_{2n-1}\le x_{2n}$

យើងនឹងបង្ហាញថា $x_{2n+1}\le x_{2n+2}$

យើងមាន $x_{2n+2}=\frac{x_{2n+1}+x_{2n}}{2}\Rightarrow x_{2n+2}-x_{2n}=\frac{x_{2n+1}+x_{2n}}{2}-x_{2n}=\frac{x_{2n+1}-x_{2n}}{2}\le 0$

ព្រោះ $x_{2n+1}=\frac{x_{2n}+x_{2n-1}}{2}\le\frac{x_{2n}+x_{2n}}{2}=x_{2n}$

គេបាន $x_{2n-1}\le x_{2n}$ ចំពោះគ្រប់ $n\in\mathbb{N}$

យើងបាន $x_{2n+1}=\frac{x_{2n}+x_{2n-1}}{2}\ge\frac{x_{2n-1}+x_{2n-1}}{2}=x_{2n-1}$

ដូចនេះ (x_{2n+1}) ជាស្វ៊ីតកើន

ស្រាយដូចគ្នាដែរគេបាន (x_{2n}) ជាស្វ៊ីតចុះ

ខ) បង្ហាញថា $|x_{n+2}-x_{n+1}|=\frac{x_2-x_1}{2^n}$ ចំពោះគ្រប់ $n\in\mathbb{N}^*$

យើងមាន $x_3 = \frac{x_2 + x_1}{2} \Rightarrow x_3 - x_2 = \frac{x_2 - x_1}{2} \Rightarrow |x_3 - x_2| = \frac{x_2 - x_1}{2}$
ឧបមាថា $|x_{k+2} - x_{k+1}| = \frac{x_2 - x_1}{2^k}$
យើងនឹងបង្ហាញថា $|x_{k+3} - x_{k+2}| = \frac{x_2 - x_1}{2^{k+1}}$
យើងមាន $|x_{k+3} - x_{k+2}| = \left|\frac{x_{k+2} + x_{k+1}}{2} - x_{k+2}\right| = \frac{|x_{k+2} - x_{k+1}|}{2} = \frac{|x_2 - x_1|}{2^{k+1}}$
ដូចនេះ $|x_{n+2} - x_{n+1}| = \frac{x_2 - x_1}{2^n}$ ចំពោះគ្រប់ $n \in \mathbb{N}^*$
គ) បង្ហាញថា $2x_{n+2} + x_{n+1} = 2x_2 + x_1$ ចំពោះគ្រប់ $n \in \mathbb{N}^*$
យើងមាន $2x_{n+2} + x_{n+1} = 2\left(\frac{x_{n+1} + x_n}{2}\right) + x_{n+1} = x_{n+1} + x_n + x_{n+1} = 2x_{n+1} + x_n$ ចំពោះគ្រប់ $n \in \mathbb{N}^*$
នេះបញ្ជាក់ថា $\{2x_{n+1} + x_n\}$ ជាស្វីតថេរ $\Rightarrow 2x_{n+2} + x_{n+1} = 2x_2 + x_1$
ដូចនេះ $2x_{n+2} + x_{n+1} = 2x_2 + x_1$ ចំពោះគ្រប់ $n \in \mathbb{N}^*$
ឃ) បង្ហាញថា (x_n) ជាស្វីតរួម ហើយមានលីមីត $\frac{x_1 + 2x_2}{3}$
តាម ក (x_{2n+1}) ជាស្វីតកើន ហើយ (x_{2n}) ជាស្វីតចុះ
ម៉្យាងទៀត $x_1 \le x_2$ នោះ (x_{2n+1}) និង (x_{2n})ជាស្វីតរួម និង មានលីមីតស្មើគ្នា
នោះ (x_n) ជាស្វីតរួម
យក l ជាលីមីត គឺ $\lim_{n\to+\infty} x_n = l$
តាម គ យើងមាន $2x_{n+2} + x_{n+1} = 2x_2 + x_1$ ចំពោះគ្រប់ $n \in \mathbb{N}^*$
នោះ $2l + l = x_1 + 2x_2 \Rightarrow l = \frac{x_1 + 2x_2}{3}$
ដូចនេះ (x_n) ជាស្វីតរួម ហើយមានលីមីត $\frac{x_1 + 2x_2}{3}$

លំហាត់ ៤០

គេឲ្យ $a_n, b_n \in \mathbb{Q}$ ដែលបំពេញលក្ខខណ្ឌ $(1+\sqrt{2})^n = a_n + b_n\sqrt{2}$ ចំពោះគ្រប់ $n \in \mathbb{N}^*$ ។ គណនា $\lim_{n\to+\infty} \frac{a_n}{b_n}$ ។

ចម្លើយ

យើងមាន $(1+\sqrt{2})^n = a_n + b_n\sqrt{2}$ នោះ $(1-\sqrt{2})^n = a_n - b_n\sqrt{2}$
គេបាន $a_n = \frac{1}{2}[(1+\sqrt{2})^n + (1-\sqrt{2})^n]$
និង $b_n = \frac{1}{2\sqrt{2}}[(1+\sqrt{2})^n - (1-\sqrt{2})^n]$

គេបាន

$$\frac{a_n}{b_n} = \frac{\frac{1}{2}[(1+\sqrt{2})^n + (1-\sqrt{2})^n]}{\frac{1}{2\sqrt{2}}[(1+\sqrt{2})^n - (1-\sqrt{2})^n]}$$
$$= \sqrt{2} \times \frac{1+\left(\frac{1-\sqrt{2}}{1+\sqrt{2}}\right)^n}{1-\left(\frac{1-\sqrt{2}}{1+\sqrt{2}}\right)^n}$$

នោះ $\lim\limits_{n\to+\infty} \frac{a_n}{b_n} = \sqrt{2} \times \frac{1+0}{1-0}$

ដូចនេះ $\lim\limits_{n\to+\infty} \frac{a_n}{b_n} = \sqrt{2}$

លំហាត់ ៤១

គេឲ្យ $a > 0$ ។ គណនា $\lim\limits_{x\to 0} \frac{(a+x)^x - 1}{x}$ ។

ចម្លើយ

យើងមាន

$$\lim_{x\to 0} \frac{(a+x)^x - 1}{x} = \lim_{x\to 0} \frac{e^{x\ln(a+x)} - 1}{x}$$
$$= \lim_{x\to 0} \frac{e^{x\ln(a+x)-1}}{x\ln(a+x)} \times \lim_{x\to 0} \ln(a+x)$$
$$= \ln a$$

ដូចនេះ $\lim\limits_{x\to 0} \frac{(a+x)^x - 1}{x} = \ln a$

លំហាត់ ៤២

គេឲ្យ $|a_1 \sin x + a_2 \sin 2x + \ldots + a_n \sin nx| \leq |\sin x|$ ចំពោះគ្រប់ $x \in \mathbb{R}$ ។ បង្ហាញថា $|a_1 + 2a_2 + \ldots + na_n| \leq 1$ ។

សម្រាយ

របៀបទី ១

យើងមាន $|a_1 \sin x + a_2 \sin 2x + \ldots + a_n \sin nx| \leq |\sin x|$ ចំពោះគ្រប់ $x \in \mathbb{R}$

នោះ $\frac{|a_1 \sin x + a_2 \sin 2x + \ldots + a_n \sin nx|}{|x|} \leq \frac{|\sin x|}{|x|} = \left|\frac{\sin x}{x}\right|$

$\Rightarrow \left|a_1 \frac{\sin x}{x} + a_2 \frac{\sin 2x}{x} + \ldots + \frac{\sin nx}{x}\right| \leq \left|\frac{\sin x}{x}\right|$

នោះ $\lim\limits_{x\to 0} \left|a_1 \frac{\sin x}{x} + a_2 \frac{\sin 2x}{x} + \ldots + \frac{\sin nx}{x}\right| \leq \lim\limits_{x\to 0} \left|\frac{\sin x}{x}\right|$

ដូចនេះ $|a_1 + 2a_2 + \ldots + na_n| \leq 1$

របៀបទី ២
តាង $f(x)=a_1\sin x+a_2\sin 2x+\ldots+a_n\sin nx$
នោះ

$$\begin{aligned}|a_1+2a_2+\ldots+na_n| &= |f'(0)|\\ &= \left|\lim_{x\to 0}\frac{f(x)-f(0)}{x-0}\right|\\ &= \lim_{x\to 0}\left|\frac{f(x)}{x}\right|\\ &= \lim_{x\to 0}\left|\frac{f(x)}{\sin x}\right|\times\left|\frac{\sin x}{x}\right|\end{aligned}$$

ដោយ $|a_1\sin x+a_2\sin 2x+\ldots+a_n\sin nx|\leq|\sin x|$
នោះ $|f(x)|\leq|\sin x|\Rightarrow\left|\dfrac{f(x)}{x}\right|\leq 1$
ដូចនេះ $|a_1+2a_2+\ldots+na_n|\leq 1$

លំហាត់ ៤៣

ឧបមាថា f និង g ជាអនុគមន៍មានដេរីវេត្រង់ $x=a$ ។ គណនា

ក) $\lim\limits_{x\to a}\dfrac{xf(a)-af(x)}{x-a}$

ខ) $\lim\limits_{x\to a}\dfrac{f(x)g(a)-f(a)g(x)}{x-a}$ ។

ចម្លើយ

ដោយ f និង g ជាអនុគមន៍មានដេរីវេត្រង់ $x=a$ នោះ $f'(a)=\lim\limits_{x\to a}\dfrac{f(x)-f(a)}{x-a}$

និង $g'(a)=\lim\limits_{x\to a}\dfrac{g(x)-g(a)}{x-a}$

គណនា

ក) $\lim\limits_{x\to a}\dfrac{xf(a)-af(x)}{x-a}$

យើងមាន

$$\begin{aligned}\lim_{x\to a}\frac{xf(a)-af(x)}{x-a} &= \lim_{x\to a}\frac{xf(a)-xf(x)+xf(x)-af(x)}{x-a}\\ &= \lim_{x\to a}\frac{-x(f(x)-f(a))}{x-a}+\frac{(x-a)f(x)}{x-a}\\ &= \lim_{x\to a}f(x)-x\times\frac{f(x)-f(a)}{x-a}\\ &= f(a)-af'(a)\end{aligned}$$

ដូចនេះ $\lim\limits_{x\to a}\dfrac{xf(a)-af(x)}{x-a}=f(a)-af'(a)$

ខ) $\lim\limits_{x\to a}\dfrac{f(x)g(a)-f(a)g(x)}{x-a}$

យើងមាន

$$\begin{aligned}\lim_{x\to a}\frac{f(x)g(a)-f(a)g(x)}{x-a}&=\lim_{x\to a}\frac{f(x)g(a)-g(a)f(a)+g(a)f(a)-f(a)g(x)}{x-a}\\&=\lim_{x\to a}\frac{g(a)(f(x)-f(a))}{x-a}-\frac{f(a)(g(x)-g(a))}{x-a}\\&=g(a)f'(a)-f(a)g'(a)\end{aligned}$$

ដូចនេះ $\lim\limits_{x\to a}\dfrac{f(x)g(a)-f(a)g(x)}{x-a}=g(a)f'(a)-f(a)g'(a)$

លំហាត់ ៤៤

គេឲ្យ f ជាអនុគមន៍មានឌីផេរ៉ង់ស្យែលត្រង់ $x=a$ ។ គណនា

ក) $\lim\limits_{x\to a}\dfrac{a^nf(x)-x^nf(a)}{x-a}$

ខ) $\lim\limits_{x\to a}\dfrac{f(x)e^x-f(a)}{f(x)\cos x-f(a)}$ ចំពោះ $a=0$ និង $f'(0)\neq 0$

គ) $\lim\limits_{n\to+\infty}n\left[f\left(1+\dfrac{1}{n}\right)+f\left(1+\dfrac{2}{n}\right)+\ldots+f\left(1+\dfrac{k}{n}\right)-kf(a)\right]$

ឃ) $\lim\limits_{n\to+\infty}n\left[f\left(1+\dfrac{1}{n^2}\right)+f\left(1+\dfrac{2}{n^2}\right)+\ldots+f\left(1+\dfrac{n}{n^2}\right)-nf(a)\right]$ ។

ចម្លើយ

ក) $\lim\limits_{x\to a}\dfrac{a^nf(x)-x^nf(a)}{x-a}$

ដោយ f មានឌីផេរ៉ង់ស្យែលត្រង់ $x=a$ នោះ $f'(a)=\lim\limits_{x\to a}\dfrac{f(x)-f(a)}{x-a}$

យើងមាន

$$\begin{aligned}\lim_{x\to a}\frac{a^nf(x)-x^nf(a)}{x-a}&=\lim_{x\to a}\frac{a^nf(x)-a^nf(a)+a^nf(a)-x^nf(a)}{x-a}\\&=\lim_{x\to a}a^n\times\frac{f(x)-f(a)}{x-a}-\frac{x^n-a^n}{x-a}\times f(a)\\&=a^nf'(a)-\lim_{x\to a}\frac{(x-a)(x^{n-1}+x^{n-2}a+\ldots+a^{n-1})}{x-a}\times f(a)\\&=a^nf'(a)-\lim_{x\to a}(x^{n-1}+x^{n-2}a+\ldots+a^{n-1})f(a)\\&=a^nf'(a)-(a^{n-1}+a^{n-1}+\ldots+a^{n-1})f(a)\\&=a^nf'(a)-na^{n-1}f(a)\end{aligned}$$

ដូចនេះ $\lim\limits_{x\to a}\dfrac{a^n f(x)-x^n f(a)}{x-a}=a^n f'(a)-na^{n-1}f(a)$

ខ) $\lim\limits_{x\to a}\dfrac{f(x)e^x-f(a)}{f(x)\cos x-f(a)}$ ចំពោះ $a=0$ និង $f'(0)\neq 0$

យើងមាន

$$\lim_{x\to a}\frac{f(x)e^x-f(a)}{f(x)\cos x-f(a)}=\lim_{x\to 0}\frac{f(x)e^x-f(0)}{f(x)\cos x-f(0)}$$
$$=\lim_{x\to 0}\frac{f(x)e^x-f(0)}{x}\times\frac{x}{f(x)\cos x-f(0)}$$
$$=\lim_{x\to 0}\frac{f(x)e^x-f(0)e^x+f(0)e^x-f(0)}{x}\times\frac{x}{f(x)\cos x-f(0)\cos x+f(0)\cos x-f(0)}$$
$$=\lim_{x\to 0}\frac{e^x[f(x)-f(0)]+f(0)e^x-f(0)}{x}\times\frac{x}{\cos x[f(x)-f(0)]+f(0)(\cos x-1)}$$
$$=\lim_{x\to 0}\left[e^x\left(\frac{f(x)-f(0)}{x}\right)+f(0)\left(\frac{e^x-1}{x}\right)\right]\times\frac{1}{\left(\frac{f(x)-f(0)}{x}\right)\cos x+\left(\frac{\cos x-1}{x}\right)f(0)}$$
$$=[f'(0)+f(0)]\times\frac{1}{f'(0)}$$
$$=1+\frac{f(0)}{f'(0)}$$

ដូចនេះ $\lim\limits_{x\to a}\dfrac{f(x)e^x-f(a)}{f(x)\cos x-f(a)}=1+\dfrac{f(0)}{f'(0)}$

គ) $\lim\limits_{n\to+\infty}n\left[f\left(a+\dfrac{1}{n}\right)+f\left(a+\dfrac{2}{n}\right)+\ldots+f\left(a+\dfrac{k}{n}\right)-kf(a)\right]$

យើងមាន

$$\lim_{n\to+\infty}n\left[f\left(a+\frac{1}{n}\right)+f\left(a+\frac{2}{n}\right)+\ldots+f\left(a+\frac{k}{n}\right)-kf(a)\right]$$
$$=\lim_{n\to+\infty}n\sum_{i=1}^{k}f\left(a+\frac{i}{n}\right)-f(a)$$
$$=\sum_{k=1}^{n}i\times\lim_{n\to+\infty}\frac{f\left(a+\frac{i}{n}\right)-f(a)}{\frac{i}{n}}$$
$$=\sum_{k=1}^{n}if'(a)$$
$$=\frac{k(k+1)}{2}f'(a)$$

ដូចនេះ $\lim_{n\to+\infty} n\left[f\left(a+\frac{1}{n}\right)+f\left(a+\frac{2}{n}\right)+...+f\left(a+\frac{k}{n}\right)-kf(a)\right]=\frac{k(k+1)}{2}f'(a)$

ឃ) $\lim_{n\to+\infty} f\left(1+\frac{1}{n^2}\right)+f\left(1+\frac{2}{n^2}\right)+...+f\left(1+\frac{n}{n^2}\right)-nf(a)$

យើងមាន

$$\begin{aligned}
&\lim_{n\to+\infty} f\left(a+\frac{1}{n^2}\right)+f\left(a+\frac{2}{n^2}\right)+...+f\left(a+\frac{n}{n^2}\right)-nf(a)\\
&=\lim_{n\to+\infty}\sum_{k=1}^{n} f\left(a+\frac{k}{n^2}\right)-f(a)\\
&=\lim_{n\to+\infty}\sum_{k=1}^{n}\frac{f\left(a+\frac{k}{n^2}\right)-f(a)}{\frac{k}{n^2}}\times\frac{k}{n^2}\\
&=\lim_{n\to+\infty}\sum_{k=1}^{n}\frac{k}{n^2}f'(a)\\
&=\lim_{n\to+\infty}\frac{n(n+1)}{2n^2}f'(a)=\frac{1}{2}f'(a)
\end{aligned}$$

ដូចនេះ $\lim_{n\to+\infty} n\left[f\left(1+\frac{1}{n^2}\right)+f\left(1+\frac{2}{n^2}\right)+...+f\left(1+\frac{n}{n^2}\right)-nf(a)\right]=\frac{1}{2}f'(a)$

លំហាត់ ៤៥

គេឲ្យស្វ៊ីត (a_n) កំណត់ដោយ $a_1=\frac{3}{2}$ និង $a_{n+1}=\frac{a_n^2-a_n+1}{a_n}$ ។ បង្ហាញថា (a_n) ជាស្វ៊ីតរួម និង គណនាលីមីតរបស់វា ។

ចម្លើយ

យើងមាន $a_1>0$

ឧបមាថា $a_n>0$

កន្សោម $a_n^2-a_n+1$ មាន $\Delta=1-4=-3<0$

នោះ $a_n^2-a_n+1>0$ ចំពោះគ្រប់ $a_n\in\mathbb{R}$

យើងបាន $a_{n+1}=\frac{a_n^2-a_n+1}{a_n}>0$

ហេតុនេះ $a_n>0$ ចំពោះគ្រប់ $n\in\mathbb{N}$

តាមវិសមភាព Cauchy យើងបាន $a_{n+1}=\frac{a_n^2-a_n+1}{a_n}=a_n+\frac{1}{a_n}-1\geq 2-1=1$

នេះបញ្ជាក់ថា (a_n) ជាស្វ៊ីតទាល់ក្រោម

ម្យ៉ាងទៀត $a_{n+1}-a_n=\frac{1}{a_n}-1\leq 0$

នោះ (a_n) គឺជាស្វ៊ីតចុះ

យើងបាន (a_n) គឺជាស៊ីតរួម
ឧបមាថា l គឺជាលីមីតនៃស៊ីត (a_n)
ដោយ $a_{n+1} = \dfrac{a_n^2 - a_n + 1}{a_n}$ យើងបាន $l = \dfrac{l^2 - l + 1}{l} \Rightarrow l = 1$
ដូចនេះ (a_n) ជាស៊ីតរួម និង មានលីមីតស្មើនឹង 1

លំហាត់ ៤៦

គេឲ្យស៊ីត (x_n) មួយកំណត់ដោយ $x_0 \in (0,1)$ និង $x_{n+1} = x_n - x_n^2 + x_n^3 - x_n^4$ ចំពោះគ្រប់ $n \geq 0$ ។ បង្ហាញថា (x_n) គឺជាស៊ីតរួម និង គណនាលីមីតរបស់វា ។

ចម្លើយ

តាមបម្រាប់ $x_0 \in (0,1)$
ឧបមាថា $0 < x_n < 1$
យើងនឹងបង្ហាញថា $0 < x_{n+1} < 1$
យើងមាន

$$\begin{aligned} x_{n+1} &= x_n - x_n^2 + x_n^3 - x_n^4 \\ &= x_n(1 - x_n + x_n^2 - x_n^3) \\ &= x_n[(1 - x_n) + x_n^2(1 - x_n)] \\ &= x_n(1 - x_n)(1 + x_n^2) \\ &\leq \left(\frac{x_n + 1 - x_n + 1 + x_n^2}{3}\right)^3 \\ &= \left(\frac{2 + x_n^2}{3}\right)^3 < \left(\frac{2+1}{3}\right)^3 = 1 \end{aligned}$$

$\Rightarrow x_n < 1$ ចំពោះគ្រប់ $n \geq 0$
គេបាន $x_{n+1} = x_n(1 - x_n)(1 + x_n^2) > 0$ ចំពោះគ្រប់ $n \in \mathbb{N}$ និង $x_0 \in (0,1) \Rightarrow x_n > 0$ ចំពោះគ្រប់ $n \geq 0$
នេះបញ្ជាក់ថា (x_n) គឺជាស៊ីតទាល់ក្រោម
ម៉្យាងទៀត

$$\begin{aligned} x_{n+1} - x_n &= -x_n^2 + x_n^3 - x_n^4 \\ &= -x_n^2(1 - x_n + x_n^2) < 0 \end{aligned}$$

នោះ (x_n) គឺជាស៊ីតចុះ
$\Rightarrow (x_n)$ គឺជាស៊ីតរួម

ឧបមាថា l គឺជាលីមីតនៃស៊ីត (x_n)
តាម $x_{n+1} = x_n - x_n^2 + x_n^3 - x_n^4$ គេបាន $l = l - l^2 + l^3 - l^4 \Rightarrow l = 0$
ដូចនេះ (x_n) ជាស៊ីតរួម និង មានលីមីត 0

លំហាត់ ៤៧
គេឲ្យ $a > 0$ និង $b \in (a, 2a)$ ។ យក (x_n) ជាស៊ីតកំណត់ដោយ $x_0 = b$ និង $x_{n+1} = a + \sqrt{x_n(2a - x_n)}$ ចំពោះគ្រប់ $n \geq 0$ ។ សិក្សាភាពរួមនៃ (x_n) ។

សម្រាយ
យើងមាន $x_0 = b$ និង $x_{n+1} = a + \sqrt{x_n(2a - x_n)}$
នោះ

$$\begin{aligned} x_1 &= a + \sqrt{x_0(2a - x_0)} \\ &= a + \sqrt{b(2a - b)} \end{aligned}$$

ហើយ

$$\begin{aligned} x_2 &= a + \sqrt{x_1(2a - x_1)} \\ &= a + \sqrt{[a + \sqrt{b(2a-b)}][a - \sqrt{b(2a-b)}]} \\ &= a + \sqrt{a^2 - b(2a - b)} \\ &= a + \sqrt{a^2 - 2ab + b^2} \\ &= a + \sqrt{(b-a)^2} = a + b - a = b \end{aligned}$$

គេបាន (x_n) ជាស៊ីតខួប គឺ $x_{2k} = b$ និង $x_{2k-1} = a + \sqrt{b(2a - b)}$
ដើម្បីឲ្យ (x_n) ជាស៊ីតរួម លុះត្រាតែ $\lim_{k\to+\infty} x_{2k} = \lim_{k\to+\infty} x_{2k-1}$
ដោយ $\lim_{k\to+\infty} x_{2k} = b$ និង $\lim_{k\to+\infty} x_{2k} = a + \sqrt{b(2a - b)}$
នោះ $b = a + \sqrt{b(2a - b)}$
$\Rightarrow (b - a)^2 = b(2a - b) \Rightarrow b^2 - 2ab + a^2 = 2ab - b^2$
$\Rightarrow 2b^2 - 4ab + a^2 = 0$
មាន $\Delta' = 4a^2 - 2a^2 = 2a^2$
យើងបាន $b = \dfrac{2a \pm \sqrt{2a^2}}{2} = a \pm a\dfrac{\sqrt{2}}{2} = a(1 \pm \dfrac{\sqrt{2}}{2})$
តែ $b > a$ នោះ $b = a(1 + \dfrac{\sqrt{2}}{2})$
ដូចនេះ (x_n) ជាស៊ីតរួមចំពោះ $b = a(1 + \dfrac{\sqrt{2}}{2})$ ហើយលីមីតរបស់វាស្មើនឹង b

លំហាត់ ៤៨

គណនា $\lim_{n\to+\infty}\sum_{k=1}^{n}\frac{k}{4k^4+1}$ ។

ចម្លើយ

យើងមាន

$$\begin{aligned}\frac{k}{4k^4+1} &= \frac{k}{4k^4+2(2k^2)+1-(2(2k^2))}\\ &= \frac{k}{(2k^2+1)^2-(2k)^2}\\ &= \frac{k}{(2k^2-2k+1)(2k^2+2k+1)}\\ &= \frac{1}{4}\left(\frac{1}{2k^2-2k+1}-\frac{1}{2k^2+2k+1}\right)\\ &= \frac{1}{4}\left[\frac{1}{2k(k-1)+1}-\frac{1}{2k(k+1)+1}\right]\end{aligned}$$

នោះ

$$\begin{aligned}\sum_{k=1}^{n}\frac{k}{4k^4+1} &= \sum_{k=1}^{n}\frac{1}{4}\left[\frac{1}{2k(k-1)+1}-\frac{1}{2k(k+1)+1}\right]\\ &= \frac{1}{4}\left[1-\frac{1}{2n(n+1)+1}\right]\end{aligned}$$

ហេតុនេះ $\lim_{n\to+\infty}\sum_{k=1}^{n}\frac{k}{4k^4+1} = \lim_{n\to+\infty}\frac{1}{4}\left[1-\frac{1}{2n(n+1)+1}\right] = \frac{1}{2}$

លំហាត់ ៤៩

គណនា $\lim_{n\to+\infty}\left(n+1-\sum_{i=2}^{n}\sum_{k=2}^{i}\frac{k-1}{k!}\right)$ ។

ចម្លើយ

យើងមាន

$$\begin{aligned}
&\lim_{n\to+\infty}\left(n+1-\sum_{i=2}^{n}\sum_{k=2}^{i}\frac{k-1}{k!}\right)\\
&=\lim_{n\to+\infty}\left[n+1-\sum_{i=2}^{n}\sum_{k=2}^{i}\left(\frac{1}{(k-1)!}-\frac{1}{k!}\right)\right]\\
&=\lim_{n\to+\infty}\left[n+1-\sum_{i=2}^{n}\left(1-\frac{1}{i!}\right)\right]\\
&=\lim_{n\to+\infty}\left(1+\sum_{i=1}^{n}\frac{1}{i!}\right)=e
\end{aligned}$$

លំហាត់ ៥០

គណនា $\lim\limits_{n\to+\infty}\dfrac{1^1+2^2+3^3+\ldots+n^n}{n^n}$ ។

ចម្លើយ

តាមទ្រឹស្តីបទ Cesaro-Stolz យើងបាន

$$\begin{aligned}
\lim_{n\to+\infty}\frac{1^1+2^2+3^3+\ldots+n^n}{n^n}&=\lim_{n\to+\infty}\frac{(n+1)^{n+1}}{(n+1)^{n+1}-n^n}\\
&=\lim_{n\to+\infty}\frac{\left(1+\frac{1}{n}\right)^{n+1}}{\left(1+\frac{1}{n}\right)^{n+1}-\frac{1}{n}}\\
&=\frac{e}{e-0}=1
\end{aligned}$$

លំហាត់ ៥១

គេឲ្យស្វ៊ីត (a_n) កំណត់ដោយ $a_0=2$ និង $a_{n-1}-a_n=\dfrac{n}{(n+1)!}$ ចំពោះ $n\geq 1$ ។

គណនា $\lim\limits_{n\to+\infty}(n+1)!\ln a_n$ ។

ចម្លើយ

យើងមាន $a_{k-1}-a_k=\dfrac{k}{(k+1)!}$ នោះ $a_k-a_{k-1}=-\dfrac{k}{(k+1)!}=\dfrac{1}{(k+1)!}-\dfrac{1}{k!}$ ចំពោះ $1\leq k\leq n$

នោះ $\sum\limits_{k=1}^{n}a_k-a_{k-1}=\sum\limits_{k=1}^{n}\dfrac{1}{(k+1)!}-\dfrac{1}{k!}$

$\Rightarrow a_n-a_0=\dfrac{1}{(n+1)!}-1$

គេបាន $a_n=a_0+\dfrac{1}{(n+1)!}-1=2+\dfrac{1}{(n+1)!}-1=1+\dfrac{1}{(n+1)!}$

ហេតុនេះ

$$\begin{aligned}\lim_{n\to+\infty}(n+1)!\ln a_n &= \lim_{n\to+\infty}(n+1)!\ln\left[1+\frac{1}{(n+1)!}\right]\\ &= \lim_{n\to+\infty}\ln\left[1+\frac{1}{(n+1)!}\right]^{(n+1)!}\\ &= \ln e = 1\end{aligned}$$

លំហាត់ ៥២

គេឲ្យស្វ៊ីតចំនួនពិត (x_n) កំណត់ដោយ $x_1 = a > 0$ និង $x_{n+1} = \dfrac{x_1+2x_2+3x_3+...+nx_n}{n}$ ចំពោះ $n\in\mathbb{N}$ ។ គណនា $\lim\limits_{n\to+\infty} x_n$ ។

ចម្លើយ

ដោយ $x_1 = a > 0$ និង $x_{n+1} = \dfrac{x_1+2x_2+3x_3+...+nx_n}{n}$

នោះ $x_n > 0$ ចំពោះគ្រប់ $n\in\mathbb{N}$

គេបាន $x_{n+1}-x_n = \dfrac{x_1+2x_2+3x_3+...+nx_n}{n} - x_n = \dfrac{x_1+2x_2+...+(n-1)x_{n-1}}{n} > 0$

គេបាន (x_n) ជាស្វ៊ីតកើន$\Rightarrow x_n > a$ ចំពោះគ្រប់ $n\geq 2$

នោះ $x_{n+1} > \dfrac{a+2a+3a+...+na}{n} = \dfrac{n(n+1)a}{2n} = \dfrac{(n+1)a}{2}$

ដូចនេះ $\lim\limits_{n\to+\infty} x_n = +\infty$

លំហាត់ ៥៣

គេឲ្យ $n\in\mathbb{N}$ ។ គណនា $\lim\limits_{x\to 0}\dfrac{1-\cos x\cos 2x...\cos nx}{x^2}$ ។

ចម្លើយ

តាង $a_n = \lim\limits_{x\to 0}\dfrac{1-\cos x\cos 2x...\cos nx}{x^2}$

នោះ $a_0 = \lim\limits_{n\to+\infty}\dfrac{1-cos0}{x^2} = 0$

យើងមាន

$$\begin{aligned}
a_{n+1} &= \lim_{x\to 0}\frac{1-\cos x\cos 2x\ldots\cos nx\cos(n+1)x}{x^2}\\
&= \lim_{x\to 0}\frac{1-\cos x\cos 2x\ldots\cos nx}{x^2}\\
&+ \lim_{x\to 0}\frac{\cos x\cos 2x\ldots\cos nx(1-\cos(n+1)x)}{x^2}\\
&= a_n + \lim_{x\to 0}\frac{1-\cos(n+1)x}{x^2}\\
&= a_n + \lim_{x\to 0}\frac{2\sin^2\frac{(n+1)x}{2}}{x^2}\\
&= a_n + \frac{(n+1)^2}{2}\lim_{x\to 0}\left[\frac{\sin\frac{(n+1)x}{2}}{\left(\frac{n+1}{2}\right)x}\right]^2\\
&= a_n + \frac{(n+1)^2}{2}\\
\Rightarrow a_{n+1}-a_n &= \frac{(n+1)^2}{2}
\end{aligned}$$

យើងបាន $\sum_{k=0}^{n-1}(a_{k+1}-a_k) = \sum_{k=0}^{n-1}\frac{(k+1)^2}{2}$

នោះ $a_n - a_0 = \sum_{k=1}^{n}\frac{k^2}{2} = \frac{n(n+1)(n+2)}{12} \Rightarrow a_n = \frac{n(n+1)(n+2}{12} + a_0$ ដោយ $a_0 = 0$

ដូចនេះ $a_n = \frac{n(n+1)(n+2)}{12}$

លំហាត់ ៥៤

គេឲ្យ f ជាអនុគមន៍កំណត់ដោយ $f(0)=0$ និង មានឌីផេរ៉ង់ស្យែលត្រង់ 0 ។ ចំពោះ $k\in\mathbb{N}$ គណនា $\lim_{x\to 0}\frac{1}{x}\left[f(x)+f\left(\frac{x}{2}\right)+f\left(\frac{x}{3}\right)+\ldots+f\left(\frac{x}{k}\right)\right]$ ។

ចម្លើយ

ដោយ $f(0)=0$ និង f មានឌីផេរ៉ង់ស្យែលត្រង់ $x=0$ គេបាន

$$\begin{aligned}
\lim_{x\to 0}\frac{1}{x}\left[f(x)+f\left(\frac{x}{2}\right)+f\left(\frac{x}{3}\right)+...+f\left(\frac{x}{k}\right)\right] &= \lim_{x\to 0}\frac{1}{x}\sum_{n=1}^{k} f\left(\frac{x}{n}\right)\\
&= \lim_{x\to 0}\sum_{n=1}^{k}\frac{f\left(\frac{x}{n}\right)}{\frac{x}{n}}\times\frac{1}{n}\\
&= \sum_{n=1}^{k}\lim_{x\to 0}\frac{f\left(\frac{x}{n}\right)-f(0)}{\frac{x}{n}-0}\times\frac{1}{n}\\
&= \sum_{n=1}^{k}\frac{1}{n}\times f'(0)\\
&= \left(1+\frac{1}{2}+...+\frac{1}{k}\right)f'(0)
\end{aligned}$$

ដូចនេះ $\lim_{x\to 0}\frac{1}{x}\left[f(x)+f\left(\frac{x}{2}\right)+f\left(\frac{x}{3}\right)+...+f\left(\frac{x}{k}\right)\right]=\left(1+\frac{1}{2}+...+\frac{1}{n}\right)f'(0)$

លំហាត់ ៥៥

គេឲ្យ $k,m\in\mathbb{N}$ ។ គណនា

ក) $\lim_{n\to+\infty}\frac{(n+1)^m+(n+2)^m+...+(n+k)^m}{n^{m-1}}-kn$

ខ) $\lim_{n\to+\infty}\frac{\left(a+\frac{1}{n}\right)^n\left(a+\frac{2}{n}\right)^n...\left(a+\frac{k}{n}\right)^n}{a^{nk}}$

គ) $\lim_{n\to+\infty}\left(1+\frac{a}{n^2}\right)\left(1+\frac{2a}{n^2}\right)...\left(1+\frac{na}{n^2}\right)$ ។

ចម្លើយ

គណនា

ក) $\lim_{n\to+\infty}\frac{(n+1)^m+(n+2)^m+...+(n+k)^m}{n^{m-1}}-kn$

យើងមាន

$$\begin{aligned}
&\lim_{n\to+\infty}\frac{(n+1)^m+(n+2)^m+...+(n+k)^m}{n^{m-1}}-kn\\
&=\lim_{n\to+\infty}\frac{(n+1)^m+(n+2)^m+...+(n+k)^m-kn^m}{n^{m-1}}\\
&=\lim_{n\to+\infty}\sum_{i=1}^{k}\frac{(n+i)^m-n^m}{n^{m-1}}\\
&=\lim_{n\to+\infty}\sum_{i=1}^{k}\frac{(1+\frac{i}{n})^m-1}{\frac{i}{n}}\times i\\
&=\sum_{i=1}^{k}if'(0)\\
&=\frac{k(k+1)}{2}f'(0)
\end{aligned}$$

ដែល $f(x)=(1+x)^m$
ដោយ $f'(x)=m(1+x)^{m-1}$ នោះ $f'(0)=m$
ហេតុនេះ $\lim\limits_{n\to+\infty}\frac{(n+1)^m+(n+2)^m+...+(n+k)^m}{n^{m-1}}-kn=\frac{mk(k+1)}{2}$

ខ) $\lim\limits_{n\to+\infty}\frac{\left(a+\frac{1}{n}\right)^n\left(a+\frac{2}{n}\right)^n...\left(a+\frac{k}{n}\right)^n}{a^{nk}}$

យក $A=\lim\limits_{n\to+\infty}\frac{\left(a+\frac{1}{n}\right)^n\left(a+\frac{2}{n}\right)^n...\left(a+\frac{k}{n}\right)^n}{a^{nk}}$

$$\begin{aligned}
\Rightarrow\ln A&=\lim_{n\to+\infty}\ln\frac{\left(a+\frac{1}{n}\right)^n\left(a+\frac{2}{n}\right)^n...\left(a+\frac{k}{n}\right)^n}{a^{nk}}\\
&=\lim_{n\to+\infty}n\ln\left(a+\frac{1}{n}\right)+n\ln\left(a+\frac{2}{n}\right)+...+n\ln\left(a+\frac{k}{n}\right)-nk\ln a\\
&=\lim_{n\to+\infty}n\sum_{i=1}^{k}\ln\left(a+\frac{i}{n}\right)-\ln a\\
&=\lim_{n\to+\infty}\sum_{i=1}^{k}\frac{\ln\left(a+\frac{i}{n}\right)-\ln a}{\frac{i}{n}}\times i\\
&=\sum_{i=1}^{k}f'(0)\times i=\frac{k(k+1)}{2}\times f'(0)
\end{aligned}$$

ដែល $f(x)=\ln(a+x)\Rightarrow f'(x)=\frac{1}{a+x}$ នោះ $f'(0)=\frac{1}{a}$
ហេតុនេះ $\ln A=\frac{k(k+1)}{2}\times\frac{1}{a}=\frac{k(k+1)}{2a}$

ដូចនេះ $\lim\limits_{n\to+\infty}\dfrac{\left(a+\frac{1}{n}\right)^n\left(a+\frac{2}{n}\right)^n\dots\left(a+\frac{k}{n}\right)^n}{a^{nk}}=e^{\frac{k(k+1)}{2a}}$

គ) $\lim\limits_{n\to+\infty}\left(1+\dfrac{a}{n^2}\right)\left(1+\dfrac{2a}{n^2}\right)\dots\left(1+\dfrac{na}{n^2}\right)$

យើងមាន $A=\lim\limits_{n\to+\infty}\left(1+\dfrac{a}{n^2}\right)\left(1+\dfrac{2a}{n^2}\right)\dots\left(1+\dfrac{na}{n^2}\right)$

$$\begin{aligned}\Rightarrow \ln A &= \lim_{n\to+\infty}\ln\left(1+\frac{a}{n^2}\right)+\ln\left(1+\frac{2a}{n^2}\right)+\dots+\ln\left(1+\frac{na}{n^2}\right)\\ &= \lim_{n\to+\infty}\sum_{k=1}^{n}\ln\left(1+\frac{ka}{n^2}\right)\\ &= \lim_{n\to+\infty}\sum_{k=1}^{n}\ln a\left(\frac{1}{a}+\frac{k}{n^2}\right)\\ &= \lim_{n\to+\infty}\sum_{k=1}^{n}\ln\left(\frac{1}{a}+\frac{k}{n^2}\right)-\ln\frac{1}{a}\\ &= \lim_{n\to+\infty}\sum_{k=1}^{n}\frac{\ln\left(\frac{1}{a}+\frac{k}{n^2}\right)-\ln\frac{1}{a}}{\frac{k}{n^2}}\times\frac{k}{n^2}\\ &= \lim_{n\to+\infty}\sum_{k=1}^{n}f'(0)\times\frac{k}{n^2}\\ &= \lim_{n\to+\infty}\frac{n(n+1)}{2n^2}f'(0)\end{aligned}$$

ដែល $f(x)=\ln\left(\dfrac{1}{a}+x\right)$ នោះ $f'(x)=\dfrac{1}{\frac{1}{a}+x}\Rightarrow f'(0)=a$

គេបាន $\ln A=\lim\limits_{n\to+\infty}\dfrac{an(n+1)}{2n^2}=\dfrac{a}{2}$

ដូចនេះ $A=e^{\frac{a}{2}}$

លំហាត់ ៥៦

ឧបមាថា f ជាអនុគមន៍មានឌីផេរ៉ង់ស្យែលត្រង់ a ហើយ (x_n) និង (z_n) ជាស្វ៊ីតរួមទៅរក a ដែល $x_n<a<z_n$ ចំពោះគ្រប់ $n\in\mathbb{N}$ ។ បង្ហាញថា $\lim\limits_{n\to+\infty}\dfrac{f(x_n)-f(z_n)}{x_n-z_n}=f'(a)$ ។

សម្រាយ

យើងមាន $\dfrac{f(x_n)-f(z_n)}{x_n-z_n}=\dfrac{f(x_n)-f(a)}{x_n-a}\times\dfrac{x_n-a}{x_n-z_n}+\dfrac{f(z_n)-f(a)}{z_n-a}\times\dfrac{a-z_n}{x_n-z_n}$

ដោយ $x_n<a<z_n$ នោះ $0<\dfrac{a-z_n}{x_n-z_n}<1$ និង $0<\dfrac{x_n-a}{x_n-z_n}<1$

ម្យ៉ាងទៀត $\dfrac{a-z_n}{x_n-z_n}+\dfrac{x_n-a}{x_n-z_n}=1$

គេបាន $\frac{f(x_n)-f(z_n)}{x_n-z_n}$ នៅចន្លោះពីរចំនួន $\frac{f(x_n)-f(a)}{x_n-a}$ និង $\frac{f(z_n)-f(a)}{z_n-a}$

តាមបម្រាប់ (x_n) និង (z_n) រួមទៅរក $a \Rightarrow \lim_{n\to+\infty}\frac{f(x_n)-f(a)}{x_n-a}=\lim_{n\to+\infty}\frac{f(z_n)-f(a)}{z_n-a}=f'(a)$

ហេតុនេះ $\lim_{n\to+\infty}\frac{f(x_n)-f(z_n)}{x_n-z_n}=f'(a)$

លំហាត់ ៥៧

គេឲ្យ f ជាអនុគមន៍ជាប់លើចន្លោះបិទ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើចន្លោះបើក (a,b) ។ បើគេដឹងថា $f(a)=f(b)=0$ បង្ហាញថា មាន $\alpha\in(a,b)$ ដែល $\alpha f(x)+f'(x)=0$ ។

សម្រាយ

យក $h(x)=e^{\alpha x}f(x)$

នោះ $h(a)=e^{\alpha a}f(a)=0$ និង $h(b)=e^{\alpha b}f(b)=0$

$\Rightarrow h(a)=h(b)$

តាមទ្រឹស្តីបទ Rolle មាន $x\in(a,b)$ ដែល $h'(x)=0$

ដោយ $h'(x)=\alpha e^{\alpha x}f(x)+e^{\alpha x}f'(x)=e^{\alpha x}(\alpha f(x)+f'(x))$

យើងបាន $e^{\alpha x}(\alpha f(x)+f'(x))=0$

ដូចនេះ $\alpha f(x)+f'(x)=0$

លំហាត់ ៥៨

គេឲ្យ f និង g ជាអនុគមន៍ជាប់លើចន្លោះបិទ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើចន្លោះបើក (a,b) ។ បើគេដឹងថា $f(a)=f(b)=0$ បង្ហាញថា មាន $x\in(a,b)$ ដែល $g'(x)f(x)+f'(x)=0$ ។

ចម្លើយ

យក $h(x)=e^{g(x)}f(x)$ នោះ $h(a)=e^{g(a)}f(a)=0$ និង $h(b)=e^{g(b)}f(b)=0$

គេបាន $h(a)=h(b)$

តាមទ្រឹស្តីបទ Rolle មាន $x\in(a,b)$ ដែល $h'(x)=0$

ដោយ $h'(x)=g'(x)e^{g(x)}f(x)+e^{g(x)}f'(x)=e^{g(x)}(g'(x)f(x)+f'(x))$

យើងបាន $e^{g(x)}(g'(x)f(x)+f'(x))=0$

ដូចនេះ $g'(x)f(x)+f'(x)=0$

លំហាត់ ៥៩

គេឲ្យ f ជាអនុគមន៍ជាប់លើចន្លោះបិទ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើចន្លោះបើក (a,b) ។ ឧបមាថា $\frac{f(a)}{a}=\frac{f(b)}{b}$ បង្ហាញថា មាន $x\in(a,b)$ ដែល $xf'(x)=f(x)$ ។

ចម្លើយ

យក $h(x)=\frac{f(x)}{x}$ នោះ $h(a)=\frac{f(a)}{a}=\frac{f(b)}{b}=h(b)$ ព្រោះ $\frac{f(a)}{a}=\frac{f(b)}{b}$

តាមទ្រឹស្តីបទ Rolle មាន $x\in(a,b)$ ដែល $h'(x)=0$

ដោយ $h'(x)=\frac{xf'(x)-f(x)}{x^2}$

យើងបាន $\frac{xf'(x)-f(x)}{x^2}=0$

ដូចនេះ $xf'(x)=f(x)$

លំហាត់ ៦០

គេឲ្យ f ជាអនុគមន៍ជាប់លើចន្លោះបិទ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើចន្លោះបើក (a,b) ។ បើគេដឹងថា $f^2(b)-f^2(a)=b^2-a^2$ បង្ហាញថា សមីការ $f'(x)f(x)=x$ មានរឹសមួយយ៉ាងតិចនៅលើចន្លោះ (a,b) ។

ចម្លើយ

យក $h(x)=f^2(x)-x^2$ នោះ $h(a)=f^2(a)-a^2$ និង $h(b)=f^2(b)-b^2$

យើងបាន

$$\begin{aligned} h(b)-h(a) &= [f^2(b)-b^2]-[f^2(a)-a^2] \\ &= [f^2(b)-f^2(a)]-(b^2-a^2)=0 \end{aligned}$$

ព្រោះ $f^2(b)-f^2(a)=b^2-a^2$

នោះ $h(a)=h(b)$

តាមទ្រឹស្តីបទ Rolle មាន $x\in(a,b)$ ដែល $h'(x)=0$

ដោយ $h'(x)=2f'(x)f(x)-2x=2[f'(x)f(x)-x]$

គេបាន $2[f'(x)f(x)-x]=0$

ដូចនេះ សមីការ $f'(x)f(x)=x$ មានរឹសមួយយ៉ាងតិចនៅលើចន្លោះ (a,b)

លំហាត់ ៦១

គេឲ្យ f ជាអនុគមន៍ជាប់ និង មិនសូន្យលើ $[a,b]$ ហើយមានឌីផេរ៉ង់ស្យែលលើ (a,b) ។ បើគេដឹងថា $f(a)g(b)=f(b)g(a)$ បង្ហាញថា មាន $x\in(a,b)$ ដែល $\dfrac{f'(x)}{f(x)}=\dfrac{g'(x)}{g(x)}$ ។

សម្រាយ

យក $h(x)=\dfrac{f(x)}{g(x)}$ ដោយ $f(a)g(b)=f(b)g(a)\Rightarrow\dfrac{f(a)}{g(a)}=\dfrac{f(b)}{g(b)}$

នោះ $h(a)=\dfrac{f(a)}{g(a)}=\dfrac{f(b)}{g(b)}=h(b)$

តាមទ្រឹស្តីបទ Rolle មាន $x\in(a,b)$ ដែល $h'(x)=0$

ដោយ $h'(x)=\dfrac{f'(x)g(x)-f(x)g'(x)}{g^2(x)}$

យើងបាន $\dfrac{f'(x)g(x)-f(x)g'(x)}{g^2(x)}=0$

នោះ $\dfrac{f'(x)}{f(x)}=\dfrac{g'(x)}{g(x)}$

ដូចនេះ មាន $x\in(a,b)$ ដែល $\dfrac{f'(x)}{f(x)}=\dfrac{g'(x)}{g(x)}$

លំហាត់ ៦២

គណនា

ក) $\lim\limits_{n\to+\infty}\left(\dfrac{1^k+2^k+...+n^k}{n^{k+1}}\right)$

ខ) $\lim\limits_{n\to+\infty}\left(\dfrac{1}{n+1}+\dfrac{1}{n+2}+...+\dfrac{1}{n+n}\right)$

គ) $\lim\limits_{n\to+\infty}\left(\dfrac{n}{n^2+1}+\dfrac{n}{n^2+4}+\dfrac{n}{n^2+9}+...+\dfrac{n}{n^2+n^2}\right)$

ចម្លើយ

គណនា

ក) $\lim\limits_{n\to+\infty}\left(\dfrac{1^k+2^k+...+n^k}{n^{k+1}}\right)$

យើងមាន

$$\begin{aligned}\lim_{n\to+\infty}\left(\frac{1^k+2^k+...+n^k}{n^{k+1}}\right)&=\lim_{n\to+\infty}\frac{1}{n}\left[\left(\frac{1}{n}\right)^k+\left(\frac{2}{n}\right)^k+...+\left(\frac{n}{n}\right)^k\right]\\&=\lim_{n\to+\infty}\sum_{i=1}^{n}\frac{1}{n}\left(\frac{i}{n}\right)^k\end{aligned}$$

ពិនិត្យអនុគមន៍ f កំណត់ដោយ $f(x)=x^k$

f ជាអនុគមន៍ជាប់លើចន្លោះ $[0,1]$

បើយើងចែកអង្កត់ $[0,1]$ ជា n អង្កត់ស្មើៗគ្នាដោយស្មុីតកំណត់ដោយ (x_i) ដែល

$x_0=0, x_1=0+1\times\dfrac{1-0}{n}=\dfrac{1}{n}, x_2=0+2\times\dfrac{1-0}{n}=\dfrac{2}{n},...$ និង $x_n=0+n\times\dfrac{1-0}{n}=\dfrac{n}{n}$

ហើយ $\Delta x=\dfrac{b-a}{n}=\dfrac{1-0}{n}=\dfrac{1}{n}$

តាមនិយមន័យអាំងតេក្រាលកំណត់យើងបាន

$\displaystyle\int_0^1 f(x)dx=\lim_{n\to+\infty}\sum_{i=1}^{n}f(x_i)\Delta x=\lim_{n\to+\infty}\sum_{i=1}^{n}\frac{1}{n}\left(\frac{i}{n}\right)^k$

ដោយ $\displaystyle\int_0^1 f(x)dx=\int_0^1 x^k dx=\left[\frac{x^{k+1}}{k+1}\right]_0^1=\frac{1}{k+1}$

ដូចនេះ $\lim\limits_{n\to+\infty}\left(\dfrac{1^k+2^k+...+n^k}{n^{k+1}}\right)=\dfrac{1}{k+1}$

ខ) $\lim\limits_{n\to+\infty}\left(\dfrac{1}{n+1}+\dfrac{1}{n+2}+...+\dfrac{1}{n+n}\right)$

យើងមាន

$$\begin{aligned}
&\lim_{n\to+\infty}\left(\frac{1}{n+1}+\frac{1}{n+2}+\ldots+\frac{1}{n+n}\right)\\
&=\lim_{n\to+\infty}\left[\frac{1}{n\left(1+\frac{1}{n}\right)}+\frac{1}{n\left(1+\frac{2}{n}\right)}+\ldots+\frac{1}{n\left(1+\frac{n}{n}\right)}\right]\\
&=\lim_{n\to+\infty}\frac{1}{n}\left(\frac{1}{1+\frac{1}{n}}+\frac{1}{1+\frac{2}{n}}+\ldots+\frac{1}{1+\frac{n}{n}}\right)\\
&=\lim_{n\to+\infty}\sum_{i=1}^{n}\frac{1}{n}\left(\frac{1}{1+\frac{i}{n}}\right)\\
&=\lim_{n\to+\infty}\sum_{i=1}^{n}\Delta x f(x_i)\text{ដែល } f(x)=\frac{1}{1+x}\\
&=\int_0^1\frac{1}{1+x}dx\\
&=[\ln|x+1|]_0^1=\ln 2
\end{aligned}$$

ដូចនេះ $\lim_{n\to+\infty}\left(\frac{1}{n+1}+\frac{1}{n+2}+\ldots+\frac{1}{n+n}\right)=\ln 2$

គ) $\lim_{n\to+\infty}\left(\frac{n}{n^2+1}+\frac{n}{n^2+4}+\frac{n}{n^2+9}+\ldots+\frac{n}{n^2+n^2}\right)$

យើងមាន

$$\begin{aligned}
&\lim_{n\to+\infty}\left(\frac{n}{n^2+1}+\frac{n}{n^2+4}+\frac{n}{n^2+9}+\ldots+\frac{n}{n^2+n^2}\right)\\
&=\lim_{n\to+\infty}\left[\frac{n}{n^2\left(1+\frac{1}{n^2}\right)}+\frac{n}{n^2\left(1+\frac{4}{n^2}\right)}+\ldots+\frac{n}{n^2\left(1+\frac{n^2}{n^2}\right)}\right]\\
&=\lim_{n\to+\infty}\left[\frac{1}{n\left(1+\frac{1}{n^2}\right)}+\frac{1}{n\left(1+\frac{4}{n^2}\right)}+\ldots+\frac{1}{n\left(1+\frac{n^2}{n^2}\right)}\right]\\
&=\lim_{n\to+\infty}\sum_{i=1}^{n}\frac{1}{n}\left[\frac{1}{1+\left(\frac{i}{n}\right)^2}\right]\\
&=\lim_{n\to+\infty}\sum_{i=1}^{n}\Delta x f(x_i)\text{ ដែល } f(x)=\frac{1}{1+x^2}\\
&=\int_0^1\frac{1}{1+x^2}dx=[\arctan x]_0^1=\arctan 1=\frac{\pi}{4}
\end{aligned}$$

លំហាត់ ៦៣

ឧបមាថា $a_0, a_1, ..., a_n$ ជាចំនួនពិតវិជ្ជមានដែលបំពេញលក្ខខណ្ឌ $\frac{a_0}{n+1}+\frac{a_1}{n}+...+\frac{a_{n-1}}{2}+a_n=0$ ។ បង្ហាញថា ពហុធា $P(x)=a_0x^n+a_1x^{n-1}+...+a_n$ មានរឹសយ៉ាងហោចណាស់មួយលើចន្លោះ $(0,1)$ ។

សម្រាយ

យក $h(x)=\frac{a_0}{n+1}x^{n+1}+\frac{a_1}{n}x^n+...+\frac{a_{n-1}}{2}x^2+a_nx$

យើងបាន $h(0)=0$

ហើយ $h(1)=\frac{a_0}{n+1}+\frac{a_1}{n}+...+\frac{a_{n-1}}{2}+a_n=0$

នោះ $h(0)=h(1)$

តាមទ្រឹស្តីបទ Rolle មាន $x\in(0,1)$ ដែល $h'(x)=0$

ដោយ $h'(x)=a_0x^n+a_1x^{n-1}+...+a_n=P(x)$

គេបាន $P(x)=0$

ដូចនេះ ពហុធា $P(x)=a_0x^n+a_1x^{n-1}+...+a_n$ មានរឹសយ៉ាងហោចណាស់មួយលើចន្លោះ $(0,1)$

លំហាត់ ៦៤

ចំពោះ $a_0, a_1, ..., a_n$ ជាចំនួនពិតដែលបំពេញលក្ខខណ្ឌ

$\frac{a_0}{1}+\frac{2a_1}{2}+\frac{2^2a_2}{3}+...+\frac{2^{n-1}a_{n-1}}{n}+\frac{2^na_n}{n+1}=0$ ។

បង្ហាញថា អនុគមន៍ $f(x)=a_n\ln^n x+a_{n-1}\ln^{n-1}x+...+a_1\ln x+a_0$ មានរឹសយ៉ាងហោចណាស់មួយលើ $(1,e^2)$ ។

សម្រាយ

យក $h(x)=\frac{a_n\ln^{n+1}x}{n+1}+\frac{a_{n-1}\ln^n x}{n}+...+\frac{a_2\ln^2 x}{2}+a_0\ln x$

នោះ $h(1)=0$

ហើយ $h(e^2)=\frac{a_0}{1}+\frac{2a_1}{2}+\frac{2^2a_2}{3}+...+\frac{2^{n-1}a_{n-1}}{n}+\frac{2^na_n}{n+1}=0$

យើងបាន $h(1)=h(e^2)=0$

តាមទ្រឹស្តីបទ Rolle មាន $x\in(1,e^2)$ ដែល $h'(x)=0$

ដោយ $h'(x)=\frac{a_n\ln^n x}{x}+\frac{a_{n-1}\ln^{n-1}x}{x}+...+\frac{a_1\ln x}{x}+\frac{a_0}{x}$

យើងបាន $\frac{a_n\ln^n x}{x}+\frac{a_{n-1}\ln^{n-1}x}{x}+...+\frac{a_1\ln x}{x}+\frac{a_0}{x}=0$

នោះ $a_n\ln^n x+a_{n-1}\ln^{n-1}x+...+a_1\ln x+a_0=0$

ដូចនេះ អនុគមន៍ $f(x)=a_n\ln^n x+a_{n-1}\ln^{n-1}x+...+a_1\ln x+a_0$ មានរឹសយ៉ាងហោចណាស់មួយលើ $(1,e^2)$

លំហាត់ ៦៥

គេឲ្យ $P(x)$ ជាពហុធាដែលមានដឺក្រេ $n, n \geq 2$ ។ បង្ហាញថា បើ $P(x)$ មានរឹសទាំងអស់ជាចំនួនពិត នោះ $P'(x)$ ក៏មានរឹសទាំងអស់ជាចំនួនពិតដែរ ។

ចម្លើយ

ឧបមាថា $x_1, x_2, \ldots, x_n$ ជារឹសពិតនៃពហុធា $P(x)$ ដែល $x_1 < x_2 < \ldots < x_n$

នោះ $P(x_1) = P(x_2) = \ldots = P(x_n)$

តាមទ្រឹស្តីបទ Rolle មាន $y_k \in (x_k, x_{k+1}), k = \overline{1,n}, x_{k+1} = x_1$ ដែល $P'(y_k) = 0$

នេះបញ្ជាក់ថា $P'(x)$ ដែលមានដឺក្រេ $n-1$ មានរឹសជាចំនួនពិតចំនួន $n-1$

ដូចនេះ $P'(x)$ មានរឹសទាំងអស់ជាចំនួនពិត

លំហាត់ ៦៦

គេឲ្យ f ជាអនុគមន៍ជាប់ និង មានឌីផេរ៉ង់ស្យែលលើ $[a,b]$ ហើយ មានឌីផេរ៉ង់ស្យែលលំដាប់ ២ លើ (a,b) ។ ឧបមាថា $f(a) = f'(a) = f(b) = 0$ បង្ហាញថា មាន $x_1 \in (a,b)$ ដែល $f'(x_1) = 0$ ។

សម្រាយ

ដោយ $f(a) = f(b)$

តាមទ្រឹស្តីបទ Rolle មាន $x \in (a,b)$ ដែល $f'(x) = 0$

នោះ $f'(a) = f'(x) = 0$

តាមទ្រឹស្តីបទ Rolle មាន $x_1 \in (a,x)$ ដែល $f''(x_1) = 0$

ដូចនេះ មាន $x_1 \in (a,b)$ ដែល $f'(x_1) = 0$

លំហាត់ ៦៧

គេឲ្យ f ជាអនុគមន៍ជាប់ និង មានឌីផេរ៉ង់ស្យែលលើចន្លោះ $[a,b]$ ហើយ មានឌីផេរ៉ង់ស្យែលលំដាប់ ២ លើចន្លោះ (a,b) ។ ឧបមាថា $f(a) = f(b)$ និង $f'(a) = f'(b) = 0$ បង្ហាញថា មាន $x_1, x_2 \in (a,b)$ ដែល $x_1 \neq x_2$ និង $f''(x_1) = f''(x_2)$ ។

សម្រាយ

ដោយ $f(a) = f(b)$

តាមទ្រឹស្តីបទ Rolle មាន $x \in (a,b)$ ដែល $f'(x) = 0$

តាមបម្រាប់ $f'(a) = f'(b) = 0$

គេបាន $f'(a) = f'(x) = f'(b) = 0$

នោះតាមទ្រឹស្តីបទ Rolle មាន $x_1 \in (a,x)$ និង $x_2 \in (x,b)$ ដែល $f''(x_1) = 0$ និង $f''(x_2) = 0$

ដូចនេះ មាន $x_1, x_2 \in (a,b)$ ដែល $x_1 \neq x_2$ និង $f''(x_1) = f''(x_2)$

លំហាត់ ៦៨

បង្ហាញថា សមីការ

ក) $x^{13} + 7x^3 - 5 = 0$

ខ) $3^x + 4^x = 5^x$ មានរឹសជាចំនួនពិតតែមួយគត់ ។

ចម្លើយ

បង្ហាញថា សមីការមានរឹសជាចំនួនពិតតែមួយគត់

ក) $x^{13} + 7x^3 - 5 = 0$

យក $f(x)=x^{13}+7x^3-5$
នោះ $f'(x)=13x^{12}+21x^2\geq 0$
$\Rightarrow f$ ជាអនុគមន៍កើនជានិច្ច
ដោយ $f(0)=-5$ និង $\lim\limits_{x\to+\infty} f(x)=+\infty$
តាមទ្រឹស្តីបទតម្លៃកណ្តាល សមីការ $f(x)=0$ មានរឹសតែមួយគត់លើ $(0,+\infty)$
ម្យ៉ាងទៀត ចំពោះ $x\leq 0$ គេបាន $x^{13}+7x^3-5<0$
នេះបញ្ជាក់ថាសមីការ $f(x)=0$ គ្មានរឹសចំពោះ $x\leq 0$
ដូចនេះ សមីការ $x^{13}+7x^3-5=0$ មានរឹសជាចំនួនពិតតែមួយគត់
ខ) $3^x+4^x=5^x$
ចំពោះ $x=2$ គេបាន $3^2+4^2=5^2\Leftrightarrow 25=25$ ពិត
នេះបញ្ជាក់ថា $x=2$ ជារឹសនៃសមីការ
យើងនឹងបង្ហាញថា $x=2$ ជារឹសនៃសមីការតែមួយគត់
យើងមាន $3^x+4^x=5^x\Leftrightarrow\left(\dfrac{3}{5}\right)^x+\left(\dfrac{4}{5}\right)^x=1$
ដោយ $f(x)=\left(\dfrac{3}{5}\right)^x+\left(\dfrac{4}{5}\right)^x$ ជាអនុគមន៍ចុះ ហើយ $g(x)=1$ ជាអនុគមន៍ថេរ
នោះសមីការ $f(x)=g(x)$ រឺ $\left(\dfrac{3}{5}\right)^x+\left(\dfrac{4}{5}\right)^x=1$ មានចម្លើយតែមួយគត់
ដូចនេះ សមីការមានរឹសតែមួយគត់ គឺ $x=2$

លំហាត់ ៦៩

ចំពោះចំនួនពិតមិនសូន្យ $a_1,a_2,...,a_n$ និង n ចំនួនពិតផ្សេងគ្នា $\alpha_1,\alpha_2,...,\alpha_n$ បង្ហាញថា សមីការ $a_1x^{\alpha_1}+a_2x^{\alpha_2}+...+a_nx^{\alpha_n}=0$ មានរឹសជាចំនួនពិតយ៉ាងច្រើន $n-1$ លើ $(0,+\infty)$ ។

សម្រាយ

យើងនឹងស្រាយបញ្ជាក់សំណើខាងលើដោយប្រើវិចារកំណើន
ចំពោះ $n=1$ យើងបាន $a_1x^{\alpha_1}=0\Rightarrow x^{\alpha_1}=0$ មិនអាច
នោះសមីការគ្មានរឹស
ក្នុងករណីនេះសំណើពិត
ឧបមាថាសំណើពិតចំពោះ n គឺ $a_1x^{\alpha_1}+a_2x^{\alpha_2}+...+a_nx^{\alpha_n}=0$ មានរឹសជាចំនួនពិតយ៉ាងច្រើន $n-1$ លើ $(0,+\infty)$
យើងនឹងបង្ហាញថាសមីការ $a_1x^{\alpha_1}+a_2x^{\alpha_2}+...+a_nx^{\alpha_n}+a_{n+1}x^{\alpha_{n+1}}=0$ មានរឹសជាចំនួនពិតយ៉ាងច្រើន n លើ $(0,+\infty)$
យើងមាន $a_1x^{\alpha_1}+a_2x^{\alpha_2}+...+a_nx^{\alpha_n}+a_{n+1}x^{\alpha_{n+1}}=0$
សមមូលនឹង $a_1x^{\alpha_1-\alpha_{n+1}}+a_2x^{\alpha_2-\alpha_{n+1}}+...+a_nx^{\alpha_n-\alpha_{n+1}}+a_{n+1}=0$
តាង $f(x)=a_1x^{\alpha_1-\alpha_{n+1}}+a_2x^{\alpha_2-\alpha_{n+1}}+...+a_nx^{\alpha_n-\alpha_{n+1}}+a_{n+1}$
នោះ $f'(x)=a_1(\alpha_1-\alpha_{n+1})x^{\alpha_1-\alpha_{n+1}-1}+a_2(\alpha_2-\alpha_{n+1})x^{\alpha_2-\alpha_{n+1}-1}+...$
$+a_n(\alpha_n-\alpha_{n+1})x^{\alpha_n-\alpha_{n+1}-1}$

ឧបមាថា $a_1x^{\alpha_1}+a_2x^{\alpha_2}+...+a_nx^{\alpha_n}+a_{n+1}x^{\alpha_{n+1}}=0$ មានរឹសច្រើនជាង n លើ $(0,+\infty)$
តាមទ្រឹស្តីបទ Rolle គេបាន $f'(x)=0$ មានរឹសយ៉ាងហោចណាស់ n ដែលផ្ទុយពីសម្មតិកម្ម កំណើន
$\Rightarrow a_1x^{\alpha_1}+a_2x^{\alpha_2}+...+a_nx^{\alpha_n}+a_{n+1}x^{\alpha_{n+1}}=0$ មានរឹសជាចំនួនពិតយ៉ាងច្រើន n លើ $(0,+\infty)$
ដូចនេះ សំណើត្រូវបានស្រាយបញ្ជាក់

លំហាត់ ៧០

ចំពោះ f,g និង h ជាអនុគមន៍ជាប់លើ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើ (a,b) គេកំណត់អនុគមន៍ F ដោយ $F(x)=\begin{vmatrix} f(x) & g(x) & h(x) \\ f(a) & g(a) & h(a) \\ f(b) & g(b) & h(b) \end{vmatrix}$ ចំពោះ $x\in[a,b]$។
បង្ហាញថា $\exists x_0\in(a,b)$ ដែល $f'(x_0)=0$ រួចទាញបញ្ជាក់ទ្រឹស្តីបទតម្លៃមធ្យម និង ទ្រឹស្តីបទ Cauchy ។

សម្រាយ

ដោយ $F(x)=\begin{vmatrix} f(x) & g(x) & h(x) \\ f(a) & g(a) & h(a) \\ f(b) & g(b) & h(b) \end{vmatrix}$

នោះ $F(a)=\begin{vmatrix} f(a) & g(a) & h(a) \\ f(a) & g(a) & h(a) \\ f(b) & g(b) & h(b) \end{vmatrix}=0$

និង $F(b)=\begin{vmatrix} f(b) & g(b) & h(b) \\ f(a) & g(a) & h(a) \\ f(b) & g(b) & h(b) \end{vmatrix}=0$

គេបាន $F(a)=F(b)$
ម៉្យាងទៀត f,g និង h ជាអនុគមន៍ជាប់លើ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើ (a,b)
នោះ $F(x)$ ក៏ជាអនុគមន៍ជាប់លើ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើ (a,b) ដែរ

គឺ $F'(x)=\begin{vmatrix} f'(x) & g'(x) & h'(x) \\ f(a) & g(a) & h(a) \\ f(b) & g(b) & h(b) \end{vmatrix}$

តាមទ្រឹស្តីបទតម្លៃមធ្យម $\exists x_0\in(a,b)$ ដែល $F'(x_0)=0$
+ ទាញបញ្ជាក់ទ្រឹស្តីបទតម្លៃមធ្យម

យក $g(x)=x$ និង $h(x)=1$ គេបាន $F'(x_0)=\begin{vmatrix} f'(x_0) & 1 & 0 \\ f(a) & a & 1 \\ f(b) & b & 1 \end{vmatrix}=0$

$\Rightarrow f(b)-f(a)=f'(x_0)(b-a)$
+ទាញបញ្ជាក់ទ្រឹស្តីបទ Cauchy

យក $h(x)=1$ គេបាន $F'(x_0)=\begin{vmatrix} f'(x_0) & g'(x_0) & 0 \\ f(a) & g(a) & 1 \\ f(b) & g(b) & 1 \end{vmatrix}=0$

$\Rightarrow \dfrac{f(b)-f(a)}{g(b)-g(a)} = \dfrac{f'(x_0)}{g'(x_0)}$

លំហាត់ ៧១

គេឲ្យ f ជាអនុគមន៍ជាប់លើ $[0,2]$ និង មានឌីផេរ៉ង់ស្យែលលើ $(0,2)$ ។ បើគេដឹងថា $f(0) = 0, f(1) = 1$ និង $f(2) = 2$ បង្ហាញថា $\exists x_0 \in (0,2)$ ដែល $f''(x_0) = 0$ ។

សម្រាយ

ដោយ f ជាអនុគមន៍ជាប់លើ $[0,2]$ និង មានឌីផេរ៉ង់ស្យែលលើ $(0,2)$ តាមទ្រឹស្តីបទតម្លៃមធ្យម $\exists x_1 \in (0,1)$ និង $x_2 \in (1,2)$ ដែល $f(1)-f(0) = f'(x_1)(1-0)$

$\Rightarrow f'(x_1) = 1-0 = 1$

ហើយ $f(2)-f(1) = f'(x_2)(2-1)$

$\Rightarrow f'(x_2) = 2-1 = 1$

គេបាន $f'(x_1) = f'(x_2) = 1$

តាមទ្រឹស្តីបទ Rolle $\exists x_0 \in (x_1, x_2)$ ដែល $f''(x_0) = 0$

ដូចនេះ $\exists x_0 \in (0,2)$ ដែល $f''(x_0) = 0$

លំហាត់ ៧២

គេឲ្យ f ជាអនុគមន៍ជាប់លើ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើ (a,b) ។ បើ f មិនមែនជាអនុគមន៍លីនេអ៊ែរ បង្ហាញថា $\exists x_1, x_2 \in (a,b)$ ដែល $f'(x_1) < \dfrac{f(b)-f(a)}{b-a} < f'(x_2)$ ។

សម្រាយ

ដោយ f មិនមែនជាអនុគមន៍លីនេអ៊ែរ នោះ $\exists c \in (a,b)$

ដែល $f(c) < f(a) + \dfrac{f(b)-f(a)}{b-a}(c-a)$ រឺ $f(c) > f(a) + \dfrac{f(b)-f(a)}{b-a}(c-a)$

ចំពោះ $f(c) < f(a) + \dfrac{f(b)-f(a)}{b-a}(c-a)$

យើងបាន $\dfrac{f(c)-f(a)}{c-a} < \dfrac{f(b)-f(a)}{b-a}$

និង $\dfrac{f(c)-f(b)}{c-b} > \dfrac{f(b)-f(a)}{b-a}$

យើងបាន $\dfrac{f(c)-f(a)}{c-a} < \dfrac{f(b)-f(a)}{b-a} < \dfrac{f(c)-f(b)}{c-b}$

តាមទ្រឹស្តីបទតម្លៃមធ្យមមាន $x_1, x_2 \in (a,b)$ ដែល $\dfrac{f(c)-f(a)}{c-a} = f'(x_1)$

និង $\dfrac{f(c)-f(b)}{c-b} = f'(x_2)$

ដូចនេះ $\exists x_1, x_2 \in (a,b)$ ដែល $f'(x_1) < \dfrac{f(b)-f(a)}{b-a} < f'(x_2)$

លំហាត់ ៧៣

គេឲ្យ f ជាអនុគមន៍ជាប់លើ $[0,1]$ និង មានឌីផេរ៉ង់ស្យែលលើ $(0,1)$ ។ ឧបមាថា $f(0) = f(1) = 0$ និង មាន $x_0 \in (0,1)$ ដែល $f(x_0) = 1$ បង្ហាញថា $\exists c \in (0,1)$ ដែល $|f'(c)| > 2$

។

សម្រាយ

+ ចំពោះ $x_0 \neq \frac{1}{2}$ នោះមួយក្នុងចំណោមចន្លោះ $[0,x_0]$ និង $[x_0,1]$ ត្រូវមានប្រវែងខ្លីជាង $\frac{1}{2}$

· បើ $[x_0,1]$ មានប្រវែងខ្លីជាង $\frac{1}{2}$

តាមទ្រឹស្តីបទតម្លៃមធ្យម $\exists c \in (x_0,1)$ ដែល $\frac{f(1)-f(x_0)}{1-x_0} = f'(c)$

$\Rightarrow f'(c) = -\frac{1}{1-x_0}$

តែ $x_0 > \frac{1}{2} \Rightarrow 1-x_0 < 1-\frac{1}{2} = \frac{1}{2}$

គេបាន $f'(c) < -2$

នោះ $|f'(c)| > 2$

ស្រាយដូចគ្នាករណី $[0,x_0]$ មានប្រវែងខ្លីជាង $\frac{1}{2}$

+ចំពោះ $x_0 = \frac{1}{2}$

-ករណី f ជាអនុគមន៍លីនេអ៊ែរលើ $[0,\frac{1}{2}]$ គឺ $f(x) = ax+b$

តាម $f(0) = 0$ និង $f(x_0) = 1$

គេបាន $f(x) = 2x$ ចំពោះ $\forall x \in [0,\frac{1}{2}]$

ដោយ $f'(\frac{1}{2}) = 2$ នោះ $\exists x_1 > \frac{1}{2}$ ដែល $f(x_1) > 1$

តាមទ្រឹស្តីបទតម្លៃមធ្យមយើងបាន $\frac{f(1)-f(x_1)}{1-x_1} = f'(c) \Rightarrow -\frac{f(x_1)}{1-x_1} = f'(c)$

ដោយ $1-x_1 < 1-\frac{1}{2} = \frac{1}{2}$

$\Rightarrow \frac{1}{1-x_1} > 2$

$\Rightarrow -\frac{f(x_1}{1-x_1} < -2f(x_1) < -2$

$\Rightarrow f'(c) < -2 \Rightarrow |f'(c)| > 2$

-ករណីដែល f មិនមែនជាអនុគមន៍លីនេអ៊ែលើ $[0,\frac{1}{2}]$

នោះ $\exists x_2 \in (0,\frac{1}{2})$ ដែល $f(x_2) > 2x_2$ រឺ $f(x_2) < 2x_2$

+$f(x_2) > 2x_2$

តាមទ្រឹស្តីបទតម្លៃមធ្យម $\exists c \in (0,x_2)$ ដែល $\frac{f(0)-f(x_2)}{0-x_2} = f'(c)$

$\frac{f(x_2)}{x_2} = f'(c) \Rightarrow f'(c) > 2$

នោះ $|f'(c)| > 2$

ស្រាយដូចគ្នាចំពោះ $f(x_2) < 2x_2$
សរុបមក $\exists c \in (0,1)$ ដែល $|f'(c)| > 2$

លំហាត់ ៧៤

គេឲ្យ f ជាអនុគមន៍ជាប់លើ $[a,b], a > 0$ និង មានឌីផេរ៉ង់ស្យែលលើ (a,b) ។ បង្ហាញថា $\exists x_1 \in (a,b)$ ដែល $\dfrac{bf(a) - af(b)}{b-a} = f(x_1) - x_1 f'(x_1)$ ។

សម្រាយ

ពិនិត្យ $g(x) = \dfrac{f(x)}{x}$ និង $h(x) = \dfrac{1}{x}$ ជាអនុគមន៍ជាប់លើ $[a,b]$ និង មានឌីផេរ៉ង់ស្យែលលើ (a,b)
ព្រោះ f ជាអនុគមន៍ជាប់លើ $[a,b], a > 0$ និង មានឌីផេរ៉ង់ស្យែលលើ (a,b)
តាមទ្រឹស្តីបទ Cauchy $\exists x_1 \in (a,b)$ ដែល $\dfrac{g(b) - g(a)}{h(b) - h(a)} = \dfrac{g'(x_1)}{h'(x_1)}$

$$\Rightarrow \frac{\frac{f(b)}{b} - \frac{f(a)}{a}}{\frac{1}{b} - \frac{1}{a}} = \frac{\frac{x_1 f'(x_1) - f(x_1)}{x_1^2}}{-\frac{1}{x_1^2}} = f(x_1) - x_1 f'(x_1)$$

ដូចនេះ $\exists x_1 \in (a,b)$ ដែល $\dfrac{bf(a) - af(b)}{b-a} = f(x_1) - x_1 f'(x_1)$

លំហាត់ ៧៥

ឧបមាថា $f : [a,b] \to \mathbb{R}, b - a \geq 4$ មានឌីផេរ៉ង់ស្យែលលើ (a,b) ។ បង្ហាញថា $\exists x_0 \in (a,b)$ ដែល $f'(x_0) < 1 + f^2(x_0)$ ។

សម្រាយ

ពិនិត្យ $g(x) = \arctan x$
ចំពោះ x_1, x_2 ដែល $a < x_1 < x_2 < b$ និង $x_2 - x_1 > \pi$
តាមទ្រឹស្តីបទតម្លៃមធ្យមយើងបាន $g(x_2) - g(x_1) = g'(x_0)(x_2 - x_1)$ ចំពោះ $x_0 \in (x_1, x_2)$

$\Rightarrow \arctan x_2 - \arctan x_1 = \dfrac{f'(x_0)}{1 + f^2(x_0)}(x_2 - x_1)$ ព្រោះ $g'(x) = \dfrac{f(x)}{1 + f^2(x)}$

$$\Rightarrow |\arctan x_2 - \arctan x_1| = \left| \frac{f'(x_0)}{1 + f^2(x)}(x_2 - x_1) \right| = \frac{|f'(x_0)|}{1 + f^2(x)}(x_2 - x_1)$$

តែ $-\dfrac{\pi}{2} \leq \arctan x_2 - \arctan x_1 \leq \dfrac{\pi}{2}$

$$\Rightarrow |\arctan x_2 - \arctan x_1| \leq \pi$$

$$\Rightarrow \frac{|f'(x_0)|}{1 + f^2(x_0)}(x_2 - x_1) \leq \pi$$

$$\Rightarrow \frac{|f'(x_0)|}{1 + f^2(x_0)} \leq \frac{\pi}{x_2 - x_1} < 1$$

$$\Rightarrow |f'(x_0)| < 1 + f^2(x_0)$$

ដូចនេះ $\exists x_0 \in (a,b)$ ដែល $f'(x_0) < 1 + f^2(x_0)$ ព្រោះ $f'(x_0) \leq |f'(x_0)|$

ឯកសារយោង

1. A Collection of Limits, Handout.
2. Problems in Mathematical Analysis II, Countinuity and Differential, W.J Kaczor and M.T.Nowak.
3. រួមទាំងឯកសារខ្មែរ និង បរទេសជាច្រើនទៀត